ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ



រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ រដ្ឋបាលជលផល

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ លោក ជិន ដា**

**រដ្ឋបាលជលផល**

ទូរស័ព្ទលេខៈ ០២៣ ៩៩៦ ៣៨០ ឬ ០១១៩៩០៩៩០

អ៊ីម៉ែលៈ smallfish@online.com.kh

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

DRAFT

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា(បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍ អន្តរជាតិ តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹង ស្ថាប័ន និង ប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វ ផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជ រដ្ឋាភិបាលតាម រយៈការវិភាគ ប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Suject Matter Specialist) នឹងត្រូវបានឆ្លងការ ពិនិត្យពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋាន ជំនាញ នានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារ គោល ដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និង ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះ ដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករ ដែលរស់នៅក្នុង តំបន់មាន សក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅ មូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការ ចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បី ធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រ ចតុកោណ របស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោល សម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យក ទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

DRAFT

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយ បញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័តិមានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរ បច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបម្រើការនៅក្នុង វិស័យអភិវឌ្ឍន៍កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់ ។បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបម្រើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័តិមានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈប្រភពជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងព័តិមានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុក នូវព័តិមានសំខាន់ៗ របស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ ក្រុមការងារ បអប បន្ទាប់មកអនុម័ត និងអនុញ្ញាត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

DRAFT

# ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ


**១. ការពិពណ៌នា** ........ **វែរៀរ។ ញៀ្សកមារក ទៀត ដចេិនដេ។**

**២. គោលការណ៍បច្ចេកទេស** ........ ២

២.១- ហេតុអ្វីយើងចាំបាច់ចិញ្ចឹមត្រី ? ........ ២

២.២- ការជ្រើសរើសទីកន្លែង សម្រាប់ការអភិវឌ្ឍន៍ចិញ្ចឹមត្រី ........ ៣

*២.២.១ - លក្ខណៈប្រភពទឹក* ........ ៣

*២.២.២ - លក្ខណៈតំបន់អភិវឌ្ឍន៍ការចិញ្ចឹមត្រី* ........ ៣

*២.២.៣ - លក្ខណៈសេដ្ឋកិច្ចសង្គម* ........ ៣

២.៣- របៀបជ្រើសរើសកសិករ សម្រាប់ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ........ ៣

២.៤- ការជ្រើសរើសទីតាំងជីកស្រះ ........ ៤

*២.៤.១ - ការជ្រើសរើសទីតាំង* ........ ៤

*២.៤.២ - គុណភាពដី សម្រាប់ស្រះចិញ្ចឹមត្រី* ........ ៥

*២.៤.៣ - របៀបជីកស្រះចិញ្ចឹមត្រី* ........ ៦

២.៥- ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម ........ ៧

*២.៥.១ - ការស្តារភក់បាតស្រះ* ........ ៧

*២.៥.២ - ការប្រើប្រាស់កំបោរ និងជី* ........ ៨

*២.៥.៣ - ការត្រួតពិនិត្យគុណភាពទឹក* ........ ១០

២.៦- ការជ្រើសរើសកូនត្រីពូជដាក់ចិញ្ចឹម ........ ១១

២.៧- ការដឹកជញ្ជូនកូនត្រី ........ ១៤

២.៨- ការដាក់កូនត្រីចិញ្ចឹម ........ ១៥

២.៩- ប្រភេទចំណី និងរបៀបដាក់ចំណី ........ ១៦

២.១០- ប្រភេទជី និងរបៀបដាក់ជី ........ ១៨

២.១១- ការគ្រប់គ្រងស្រះ ........ ២០

*២.១១.១ - ការត្រួតពិនិត្យគុណភាពទឹកស្រះ* ........ ២០

*២.១១.២ - កត្តសត្រួតពិនិត្យគុណភាពទឹក* ........ ២២

*២.១១.៣ - ការត្រួតពិនិត្យ កូនត្រីពូជទីឡាព្យ៉ា* ........ ២៣

*២.១១.៤ - ការព្យាយាមត្រួតពិនិត្យមើលស្រះចិញ្ចឹមត្រី* ........ ២៣

*២.១១.៥ - វិធានការការពារជម្ងឺត្រី* ........ ២៤

២.១២- ការប្រមូលផលត្រី ........ ២៤

២.១៣- ការវិភាគសេដ្ឋកិច្ច ........ ២៥

**៣. វិធីសាស្ត្រផ្សព្វផ្សាយ** ........ **វែរៀរ។ ញៀ្សកមារក ទៀត ដចេិនដេ។**

៣.១- វិធីសាស្ត្រអនុវត្ត ........ ២៦


DRAFT

៣.២- ថវិកាសម្រាប់ការធ្វើបង្ហាញ ..... ៣១

៣.៣- ធនធានសំភារៈ ..... ៣២

៣.៤- ការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាពវារីវប្បកម្ម ..... ៣២

**៤. សេចក្តីបន្ថែម ..... រឺវៀវ1 ញ្យ៉ៀកមារក ឡៀត ជចឹនដេ។**

៤.១- កត្តាសំខាន់ៗ ដែលធ្វើឱ្យត្រីពុល និងស្លាប់ និងវិធានការដោះស្រាយ ..... ៣៣

៤.២- បញ្ហាដែលតែងតែកើតមានក្នុងពេលចិញ្ចឹមត្រី និង វិធានការដោះស្រាយ ..... ៣៤

៤.៣- ការប្រមូលទិន្នន័យ ក្នុងអំឡុងពេលចិញ្ចឹមត្រី ..... ៣៦

៤.៤- ការចំណាយសម្រាប់ការធ្វើបង្ហាញបច្ចេកទេសចិញ្ចឹមត្រី (សម្រាប់ស្រះទំហំ ១០០ម$^{២}$ រយៈពេល ៨ ខែ) ..... ៣៩

៤.៥- ទីកន្លែងផលិតកូនត្រីពូជនៅប្រទេសកម្ពុជា ..... ៣៩

*៤.៥.១ - ស្ថានីយផលិតកូនត្រីពូជ របស់រាជរដ្ឋាភិបាល* ..... ៣៩

*៤.៥.២ - ស្ថានីយផលិតកូនត្រីពូជ ឯកជន* ..... ៤០

DRAFT

## ១~ ការពិពណ៌នា

### សេចក្តីសង្ខេប

**បញ្ហា** ផលិតភាពនៃការចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារនៅមានកំរិតទាប

**គោលដៅ** ដើម្បីផលិតបានត្រីទំងន់ ពី ៣០ ទៅ ៣៦គីឡូក្រាម លើស្រះទំហំ 100m$^2$ ក្នុងរយៈពេល ៨ ខែ ។

**វិធីសាស្ត្រ** ១- ត្រូវរៀបចំស្រះអោយរួចរាល់ល្អ មុនរដូវវស្សាមកដល់

២- ជ្រើសរើសកូនត្រីពូជដែលមានគុណភាពល្អ និងដឹកជញ្ជូនយកទៅដាក់ស្រះចិញ្ចឹមយ៉ាងប្រុងប្រយ័ត្ន បំផុត

៣- ត្រួតពិនិត្យតាមដានមើលទឹកស្រះជាប្រចាំដើម្បីស្ទង់ពីកំរិតចំណីធម្មជាតិដែលមានក្នុងស្រះ អោយបានល្អ

### ផលប្រយោជន៍

-កាត់បន្ថយការចំណាយប្រាក់ទិញត្រីពីទីផ្សារ

-កសិករអាចប្រើប្រាស់ផលត្រីចិញ្ចឹមបានគ្រប់ពេល បន្ទាប់ពីបានចិញ្ចឹមរយៈពេលពី ៤ ទៅ ៥ ខែ

-ប្រើប្រាស់ទុនតិចតួច ក្នុងការចិញ្ចឹមត្រី

- ក្រៅពីការប្រើប្រាស់ផលត្រីក្នុងគ្រួសារ កសិករអាចលក់ ដើម្បីរកប្រាក់ចំណូលខ្លះទៀតផង

-កសិករមិនចាំបាច់ចំណាយពេលទៅរកចាប់ត្រីពីធម្មជាតិ នៅកន្លែងផ្សេងទៀត

-កាត់បន្ថយសកម្មភាពចាប់ត្រីដោយខុសច្បាប់តាមប្រភពទឹកធម្មជាតិ

### លក្ខខណ្ឌអំណោយផលនៃបច្ចេកទេសចិញ្ចឹមត្រី

លក្ខណៈវិនិច្ឆ័យខាងក្រោមនេះ ជាលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្ត (បទដ្ឋានអនុវត្តបច្ចេកវិទ្យា) នេះ ដើម្បីសម្រេចបាននូវកម្មវត្ថុដែលបានចែងដូចខាងលើ ។

លក្ខណៈអាកាសធាតុ និង ទឹកសម្រាប់ចិញ្ចឹមត្រី:

- ស្រះចិញ្ចឹមត្រីចាំបាច់ត្រូវមានទឹករយៈពេលពី ៦ ទៅ ៨ ខែ ប៉ុន្តែបើស្រះ ឬកសិដ្ឋានផលិតកូនត្រីពូជ ត្រូវមានទឹកពេញមួយឆ្នាំ ។
- ស្រះចិញ្ចឹមត្រីចាំបាច់ត្រូវការពារកុំឱ្យលិចទឹកជំនន់ ដើម្បីជៀសវាងត្រីចិញ្ចឹមរួចចេញពីស្រះ
- ម្យ៉ាងទៀត ស្រះចិញ្ចឹមត្រីចាំបាច់ត្រូវការពារកុំឱ្យមានប្រភពទឹកពុល ដូចជា ទឹកដែលមានប្រើថ្នាំគីមី ឬថ្នាំសម្លាប់សត្វល្អិត ជាដើម ។

លក្ខណៈភូមិសាស្ត្រ:

- ការចិញ្ចឹមត្រីចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្តតាមលក្ខខណ្ឌ ដែលបានចែងខាងលើ
- ការអនុវត្តតាម (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)នេះបានជោគជ័យ ក៏អាស្រ័យនឹងការផ្គត់ផ្គង់គុណភាព កូនត្រីពូជផងដែរ ។

ទំហំកសិដ្ឋាន:

- ស្រះចិញ្ចឹមត្រីកាន់តែធំ ទទួលផលត្រីបានកាន់តែច្រើន អាស្រ័យនឹងបច្ចេកទេស និងការយកចិត្តទុកដាក់គ្រប់គ្រង ។ នៅតាមជនបទ ជាទូទៅស្រះចិញ្ចឹមត្រីមានទំហំ ពី ៨០ ទៅ ២០០ ម២ ប៉ុន្តែស្រះដែលមានទំហំតូចជាងនេះ ក៏អាចចិញ្ចឹមត្រីបានដែរ ។

តម្រូវការកម្លាំងពលកម្ម:

- សម្រាប់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារនៅតាមជនបទ ជាទូទៅកសិករប្រើប្រាស់កម្លាំងពលកម្មដែលមានក្នុងគ្រួសាររបស់គាត់ ។
- ការងាររៀបចំស្រះ និងដឹកជញ្ជូនកូនត្រីពូជ ជាធម្មតាកម្លាំងបុរស ជាអ្នកអនុវត្ត
- ចំណែកការងារអនុវត្តបច្ចេកទេសចិញ្ចឹមត្រី ផ្សេងទៀត ដូចជា ការដាក់ត្រីចិញ្ចឹម ការផ្តល់ចំណី ការគ្រប់គ្រងស្រះ និង ការប្រមូលផលត្រីចិញ្ចឹម អាចអនុវត្តដោយកម្លាំងពលកម្មដែលមានក្នុងគ្រួសារ ។

ស្ថានភាពសេដ្ឋកិច្ចនៃការចិញ្ចឹមត្រី របស់កសិករ:

- គ្រួសារកសិករដែលចិញ្ចឹមត្រីក្នុងស្រះទំហំ ១០០ ម² ដោយចំណាយទឹកប្រាក់ត្រឹមតែពី ៥០.០០០ រៀល ទៅ ៦៥.០០០ រៀល អាចអនុវត្តតាម (បទដ្ឋានអនុវត្តបច្ចេកវិទ្យា) នេះ ។
- ចិញ្ចឹមត្រីក្នុងស្រះទំហំ ១០០ ម² ក្នុងរយៈពេលប្រមាណ ៨ខែ អាចទទួលបានផលត្រី ពី ៣០ ទៅ ៣៦ គ.ក្រ

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:

*ការិយាល័យវារីវប្បកម្ម រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
*ទូរស័ព្ទលេខ: ០២៣ ៩៩៦ ៣៨០ អ៊ីម៉ែល:* smallfish@online.com.kh

## ២- គោលការណ៍បច្ចេកទេស

### ២.១- ហេតុអ្វីយើងចាំបាច់ចិញ្ចឹមត្រី ?

ប្រទេសកម្ពុជា ទិន្នផលត្រីបានផ្តល់បរិមាណប្រូតេអ៊ីនប្រមាណពី ៧០- ៧៥% ដល់ប្រជាពលរដ្ឋកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ បរិមាណផលត្រីក្នុងធម្មជាតិ ត្រូវបានធ្វើអាជីវកម្មនេសាទយ៉ាងច្រើន ទាំងផលត្រីទឹកសាប និងផលត្រីសមុទ្រ ដើម្បីបំពេញបានតម្រូវការរបស់ប្រជាពលរដ្ឋ និងសន្តិសុខស្បៀង ដែលមានកំណើនជារៀងរាល់ឆ្នាំ។ ដើម្បីបំពេញបន្ថែមនូវតម្រូវការនេះ មានតែការជំរុញអភិវឌ្ឍន៍វារីវប្បកម្មទេ ដែលបច្ចុប្បន្នចាំបាច់តម្រូវឱ្យមានសកម្មភាពកាន់តែផុសផុលឡើង ។

សកម្មភាពវារីវប្បកម្មជាលក្ខណៈគ្រួសារបច្ចុប្បន្នត្រូវបានជួយឧបត្ថម្ភគាំទ្រពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល សហការជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាលនានា ដូចជា PADEK, AIT-AARM, SCALE, MRC-AIMS, WFP, CRS, IPM និង JICA ជាដើម ។ ទោះជាយ៉ាងណាក៏ដោយ វារីវប្បករត្រូវតែយកចិត្តទុកដាក់អនុវត្តបច្ចេកទេសចិញ្ចឹមត្រីឱ្យបានល្អ ដើម្បីទទួលបានទិន្នផលត្រីខ្ពស់ ។

DRAFT

## ២.២- ការជ្រើសរើសទីកន្លែង សម្រាប់ការអភិវឌ្ឍន៍ចិញ្ចឹមត្រី

### **២.២.១** - លក្ខណៈប្រភពទឹក

ស្រះចិញ្ចឹមត្រីត្រូវការទឹកយ៉ាងហោចណាស់រយៈពេល ៦ ខែ ប៉ុន្តែត្រូវការពារកុំឱ្យលិចទឹកក្នុងពេលរដូវទឹកជំនន់ ព្រោះបណ្តាលឱ្យត្រីធម្មជាតិចូលក្នុងស្រះ ស៊ីកូនត្រីដែលបានដាក់ចិញ្ចឹម និងកូនត្រីនឹងរួចចេញពីស្រះអស់ ។ ចំពោះតំបន់ដែលមានទឹកតិច កសិករអាចដាក់ត្រីចិញ្ចឹមបានក្នុងចំនួនតិចតួច និងត្រូវដាក់មានទំហំធំ ដើម្បីឱ្យត្រីអាចរស់ក្នុងស្រះមានទឹកតិច និងមានការលូតលាស់ ។

កសិករក្រីក្រអាចចិញ្ចឹមត្រីក្នុងស្រះ ដោយពឹងផ្អែកលើទឹកភ្លៀង និងមិនចាំបាច់ចំណាយថវិកាបូមទឹក ពីក្រៅចូលក្នុងស្រះចិញ្ចឹមត្រី ។

### **២.២.២** - លក្ខណៈតំបន់អភិវឌ្ឍន៍ការចិញ្ចឹមត្រី

ចំពោះការអភិវឌ្ឍន៍បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ជាអាទិភាពគួរតែយកចិត្តទុកដាក់ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងតំបន់នៅឆ្ងាយពីប្រភពទឹកធម្មជាតិ ដែលប្រជាកសិករពុំអាចរកចាប់ត្រីធម្មជាតិមកទទួលទានប្រចាំថ្ងៃបាន ។

ប៉ុន្តែជាទូទៅ (បទដ្ឋានអនុវត្តបច្ចេកវិជ្ជានេះ) អាចអនុវត្តបានគ្រប់ទីកន្លែង ចំពោះកសិករដែល មានស្រះចិញ្ចឹមត្រី ឬមានបំណងចង់ចិញ្ចឹមត្រី និងមានពេលវេលា ថវិកាគ្រប់គ្រាន់សម្រាប់ជីកស្រះចិញ្ចឹមត្រី និងមើល ថែទាំ ។

### **២.២.៣** - លក្ខណៈសេដ្ឋកិច្ចសង្គម

គោលនយោបាយរបស់រាជរដ្ឋាភិបាល បានកំណត់ការអភិវឌ្ឍន៍ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ គឺជាអាទិភាពចំបងក្នុងការជួយកែលំអជីវភាពរស់នៅរបស់ប្រជាកសិករនៅតាមជនបទ ។ បរិមាណផលត្រីដែលបានមកពីការចិញ្ចឹមនេះ គឺបានចូលរួមចំណែកផ្តល់នូវម្ហូបអាហារមួយផ្នែកទៀតនៃមុខរបរកសិកម្ម ក្នុងកសិដ្ឋានរបស់កសិករ ។ម្យ៉ាងទៀត កសិករអាចរកប្រាក់ចំណូលពីការចិញ្ចឹមត្រីនេះ តាមរយៈការកែលំអបច្ចេកទេសចិញ្ចឹមត្រី និងបង្កើនការ ជីកស្រះចិញ្ចឹមត្រី ហើយប្រាក់ចំណូលនេះនឹងជួយសម្រួលកសិករចំណាយទៅលើសកម្មភាពផ្សេងៗ ដូចជាការជួយទំនុកបំរុងឱ្យកូនចៅទៅសាលារៀន និងសម្រាប់ទិញថ្នាំសង្កូវជាដើម ។

## ២.៣- របៀបជ្រើសរើសកសិករ សម្រាប់ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី

ខាងក្រោមនេះជាលក្ខណៈវិនិច្ឆ័យសំខាន់ៗ នៃការជ្រើសរើសកសិករសម្រាប់ការអភិវឌ្ឍន៍សកម្មភាពចិញ្ចឹមត្រី ដោយផ្អែកលើបទពិសោធន៍ និងការសិក្សាវិភាគកន្លងមក ។

**ក- បុគ្គលិកលក្ខណៈរបស់កសិករ**

- ពេញចិត្តនឹងមុខរបរការងារចិញ្ចឹមត្រី និងព្យាយាមធ្វើការងារ
- ចូលរួមសហការការងារជាមួយបុគ្គលិកផ្សព្វផ្សាយរបស់គម្រោង
- មានទំនាក់ទំនងល្អជាមួយប្រជាជនក្នុងភូមិ និងក្រៅភូមិ

DRAFT

**ខ- ធនធានរបស់កសិករ**

- មានស្រះចិញ្ចឹមត្រី ដែលអាចដក់ទឹកបានរយៈពេលពី ៦- ៨ ខែ
- មានប្រភពទឹកដែលអាចផ្គត់ផ្គង់ទឹកក្នុងស្រះចិញ្ចឹមបានពី ៦- ៨ ខែ
- មានកម្លាំងពលកម្មគ្រប់គ្រាន់
- មានប្រភពធនធានចំណីត្រី ដូចជា ចក  កណ្ដៀវ  ជន្លេន ជាដើម .....
- ធនធានមានស្រាប់ ដូចជា លាមកសត្វ
- មានទុនសម្រាប់ចិញ្ចឹមត្រី

**គ- ធនធានក្នុងភូមិ**

- មានប្រជាកសិករជាច្រើនក្នុងភូមិ និងក្រៅភូមិមានលទ្ធភាពចិញ្ចឹមត្រី
- ខ្វះខាតសាច់ត្រីទទួលទាន (ត្រីធម្មជាតិថយចុះ ក្នុងពេលរដូវភ្លៀង និងរដូវប្រាំង) ។

## ២.៤- ការជ្រើសរើសទីតាំងជីកស្រះ

ការជួលជីកស្រះថ្មីសម្រាប់ចិញ្ចឹមត្រី  ជាធម្មតាត្រូវចំណាយប្រាក់ជួលកម្លាំងពលកម្មជីក ដូចនេះមានតម្លៃថ្លៃ។ ម្យ៉ាងទៀត ចំពោះកសិករដែលមានស្រះស្រាប់   អាចពង្រីកស្រះរបស់ខ្លួនបណ្ដើរៗជារៀងរាល់ឆ្នាំ ក្នុងករណីកសិករមានកន្លែងទំនេរសម្រាប់ពង្រីកស្រះ   មានពេលវេលាពង្រីកស្រះ ដោយប្រើកម្លាំងពលកម្មក្នុងគ្រួសារ ឬ មានថវិកាជួលកម្លាំងពីខាងក្រៅមកជីក ។

### ២.៤.១ - ការជ្រើសរើសទីតាំង

ការជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រីជាបញ្ហាសំខាន់ដែលត្រូវយកចិត្តទុកដាក់  ដើម្បីជៀសវាងការចំណាយថវិកា និងកម្លាំងពលកម្មខាតប្រយោជន៍ ។  ទីកន្លែងល្អសមស្របសម្រាប់ការចិញ្ចឹមត្រី ជាកន្លែងដែលកសិករងាយស្រួលក្នុងការគ្រប់គ្រង និងត្រួតពិនិត្យស្រះចិញ្ចឹមត្រីរៀងរាល់ថ្ងៃ ដូចជា សកម្មភាពឱ្យចំណីត្រី  ការដាក់ជី  ការត្រួតពិនិត្យគុណភាពទឹក ជម្ងឺត្រី និងតាមដានការលួចចាប់ត្រីជាដើម។  សម្រាប់កសិករនៅតាមជនបទ ស្រះ ចិញ្ចឹម ត្រីត្រូវតែជីកនៅក្បែរ ឬ ជាប់ផ្ទះ  ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងារគ្រប់គ្រង ។  ក្រៅពីនេះ ទីតាំងសមស្របសម្រាប់ជីកស្រះចិញ្ចឹមត្រី  គួរមានលក្ខណៈដូចខាងក្រោមៈ

- គ្មានដើមឈើដុះគ្របដណ្ដប់ពេញលើផ្ទៃស្រះ
- ដីអាចរក្សាទឹកក្នុងស្រះបានរយៈពេលពី ៦- ៨ ខែ
- នៅជិត ឬ ជាប់នឹងវាលស្រែ  ងាយស្រួលជីកស្រះតភ្ជាប់ទៅវាលស្រែ
- នៅឆ្ងាយពីតំបន់ប្រើប្រាស់ថ្នាំពុល  ឬ ថ្នាំសម្លាប់សត្វល្អិត ។

ចូរចងចាំថា ពន្លឺថ្ងៃមានសារៈប្រយោជន៍សំខាន់ណាស់ សម្រាប់ស្រះចិញ្ចឹមត្រី  ដើម្បីបង្កើតចំណីធម្មជាតិ

DRAFT

ដែលជាចំណីដ៏មានប្រយោជន៍ និងសំខាន់បំផុតសម្រាប់ត្រី ។ ដូចនេះមិនត្រូវឱ្យមានដើមឈើដុះគ្របដណ្តប់លើផ្ទៃស្រះចិញ្ចឹមត្រី ដែលវារាំងពន្លឺថ្ងៃមិនអាចចាំងចូលស្រះបាន ម្យ៉ាងទៀតស្លឹកឈើប្រភេទខ្លះក៏មានជាតិពុលដល់ត្រីនៅពេលវាធ្លាក់ចូលក្នុងស្រះចិញ្ចឹមត្រី ។





ស្រះសមស្របសម្រាប់ចិញ្ចឹមត្រី (គ្មានដើមឈើ) ស្រះមិនល្អសម្រាប់ចិញ្ចឹមត្រី (មានដើមឈើដុះជុំវិញ)

**- គុណភាពដី សម្រាប់ស្រះចិញ្ចឹមត្រី**

ប្រភេទដីឥដ្ឋ ជាប្រភេទដីមានលក្ខណៈសមស្របសម្រាប់ជីកស្រះចិញ្ចឹមត្រី ដែលអាចរក្សាទឹកបានរយៈពេលពី ៦ ទៅ ៨ ខែ ។ ចំណែកប្រភេទដីឥដ្ឋ មានលាយដីល្បាប់ ជាប្រភេទដីមានជីច្រើន ដែលអំណោយផលល្អសម្រាប់ស្រះចិញ្ចឹមត្រី ព្រោះធ្វើឱ្យសម្បូរចំណីធម្មជាតិ និងរក្សាទឹកបានយូរទៀតផង ។

*យើងអាចសាកល្បងពិនិត្យ មើលគុណភាពដី* តើអាចជីកស្រះចិញ្ចឹមត្រីបានដែរឬទេ ដោយជីករណ្តៅមួយមានជម្រៅ 0,៨ ម និង មាត់ 0,៦ ម ។ បន្ទាប់មកចាក់ទឹកបំពេញក្នុងរណ្តៅ រួចទុកចោលរយៈពេល ២ ទៅ ៣ ថ្ងៃ ។ ក្រោយមកបើមានទឹកនៅសល់ក្នុងរណ្តៅ នោះមានន័យថា ប្រភេទដីនោះសមស្របសម្រាប់ជីកស្រះចិញ្ចឹមត្រី ។



សកម្មភាពជីករណ្តៅ ចាក់ទឹកបំពេញ ២ ថ្ងៃក្រោយនៅមានទឹកក្នុងរណ្តៅ អាចជីកស្រះចិញ្ចឹមត្រីបាន

### ២.៤.២ - **របៀបជីកស្រះចិញ្ចឹមត្រី**

ស្រះចិញ្ចឹមត្រីគួរជីកឱ្យមានរាងជាចតុកោណកែងនិងមានជើងទេរសមស្រប ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបង្កើតឱ្យមានសម្បូរចំណីធម្មជាតិផង និងសម្បូរខ្យល់អុកស៊ីសែនផង ។ ជើងទេរស្រះអាចមានជំរេល ១ៈ១ ឬ អាច ១ៈ២ សម្រាប់ប្រភេទដីដែលមានជាតិខ្សាច់ (សូមមើលរូបភាពខាងក្រោម)។ ដូចនេះ ជម្រៅស្រះអាចប្រែ ប្រួលទៅតាមប្រភេទដី ឧទាហរណ៍ ស្រះទំហំ ៨០ម២ ជម្រៅស្រះអាចជីកបានជម្រៅពី ១,៥ ម ទៅ ២ម ។






គ្រួសារកសិករកំពុងជីកស្រះចិញ្ចឹមត្រី



គំរូជីកស្រះចិញ្ចឹមត្រី

អាចម៍ដីត្រូវយកមកធ្វើទំនប់ ឬ ភ្លឺព័ទ្ធជុំវិញស្រះ ។ ជាទូទៅចំពោះអាចម៍ដីនៅស្រទាប់លើជាប្រភេទដីមានជីច្រើនជាងដីនៅស្រទាប់ក្រោម ដូចនេះត្រូវយកវាមកដាក់ក្រាលនៅស្រទាប់លើនៃភ្លឺស្រះ ដើម្បីដាំស្មៅការពារ ការហូរច្រោះនៃដីចូលក្នុងស្រះ ដែលធ្វើឱ្យទឹកស្រះល្អក់នៅពេលភ្លៀងធ្លាក់ ។ បាតស្រះត្រូវជីកឱ្យមានជម្រាលទៅ ជ្រុងខ្លីម្ខាងនៃស្រះ ដើម្បីងាយស្រួលក្នុងការប្រមូលផលត្រី ។ ចំពោះកសិករដែលមានលទ្ធភាព ក្នុងពេលលើកភ្លឺស្រះ កសិករ

អាចដាក់បំពង់ទឹកបង្ហប់ក្នុងភ្លឺស្រះសម្រាប់ការបង្ហូរទឹកចេញ ចូល ស្រះចិញ្ចឹមត្រី ។ ម្យ៉ាងទៀត ក្នុងករណី មានស្រែនៅជាប់នឹងស្រះ កសិករគួរជីកកូនចង្អូរ ឬ ប្រឡាយតភ្ជាប់ពីស្រះ ទៅប្រឡាយ ដើម្បីឱ្យត្រីចេញទៅ វាលស្រែរកចំណីបន្ថែម បង្កឱ្យត្រីមានការធំធាត់ឆាប់រហ័ស ។


ការជីកចង្អូរព័ទ្ធជុំវិញវាលស្រែ


ស្រះចិញ្ចឹមត្រីតភ្ជាប់ទៅស្រែដោយជីកចង្អូរ

ចំពោះកសិករដែលមានស្រះស្រាប់ ត្រូវយកចិត្តទុកដាក់លើកភ្លឺស្រះឱ្យខ្ពស់ និងដាំស្មៅ ដើម្បីជៀសវាងការហូរច្រោះដី ដោយសារទឹកភ្លៀង ដែលនាំឱ្យទឹកស្រះល្អក់ ។ ម្យ៉ាងទៀតត្រូវធ្វើជើងទេរស្រះឱ្យបានល្អ និងបារភក់ចេញពីបាតស្រះ ក្នុងពេលរៀបចំស្រះ (មើលចំណុចមេរៀនរៀបចំស្រះ) ។

## **២.៥- ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម**

ការរៀបចំស្រះមានសារៈសំខាន់ និងចាំបាច់បំផុត ដែលត្រូវធ្វើឱ្យបានល្អ មុនពេលដាក់ត្រីចិញ្ចឹម ។ ស្រះដែលរៀបចំបានល្អ គឺមានលក្ខណៈដូចខាងក្រោមៈ

- គ្មានត្រីស្រែ ឬ សត្វផ្សេងទៀត ដែលស៊ីកូនត្រី ។ ប៉ុន្តែចំពោះកូនត្រីមានទំហំធំជាង ១០ ស.ម វត្តមានត្រីស្រែនៅក្នុងស្រះមិនចាត់ទុកជាបញ្ហាសំខាន់ទេ ។
- ទឹកស្រះមានពណ៌បៃតងល្អ បញ្ជាក់ពីវត្តមានចំណីធម្មជាតិ ដែលមានសម្បូរក្នុងទឹកស្រះ
- ទឹកស្រះមានកំរិត pH 6.5 – 8 (កំរិតជាតិជូរនៃទឹកស្រះ)
- ទឹកស្រះស្រឡះល្អ គ្មានរុក្ខជាតិទឹកដុះគ្របដណ្តប់ពេញផ្ទៃស្រះ ។

### ២.៥.១ - **ការស្តារភក់បាតស្រះ**

ភក់បាតស្រះមានសារៈប្រយោជន៍សម្រាប់ជីវិតរស់នៅរបស់ពពួកសត្វស្រទាប់បាត ដូចជា ខ្យង ខ្ចៅ ជន្លេន ជាដើមដែលជាប្រភពចំណីសំខាន់សម្រាប់ត្រី ។ ប៉ុន្តែភក់បាតស្រះមិនអនុញ្ញាតឱ្យមានច្រើនលើសពី ២០ស.ម ទេ ពីព្រោះកាលណាភក់កាន់តែច្រើនកំរិតរលាយឧស្ម័នអ៊ុកស៊ីសែ្សនកាន់តែតិច ហើយផ្ទុយទៅវិញកំរិតរលាយឧស្ម័នពុល មេ

តាន និងអាម៉ូនីញាក់ ($CH_4$, $NH_3$) កាន់តែកើនឡើង ។ ដូចនេះ ជារៀងរាល់ឆ្នាំស្រះចិញ្ចឹមត្រីចាំបាច់ត្រូវតែ ស្តារភក់បាតស្រះចេញ ដោយទុកជម្រៅត្រឹមតែ ១៥ ទៅ ២០ ស.ម ។

### ២.៥.២ - ការប្រើប្រាស់កំបោរ និងជី

ការប្រើប្រាស់កំបោរក្នុងការរៀបចំស្រះមានសារៈសំខាន់ណាស់ ព្រោះវាបានកែលំអគុណភាពទឹកពីអាស៊ីតមកបាស បំបាត់ភាពល្អក់នៃទឹក សម្លាប់ត្រីកាច សត្វល្អិតបំផ្លាញកូនត្រី សម្លាប់មេរោគ និងជួយដល់ការប្រើប្រាស់ជីកែលំអគុណភាពទឹកឱ្យមានប្រសិទ្ធភាព។ កំបោរដែលយកមកប្រើប្រាស់នេះ ជាប្រភេទម្សៅកំបោរសលាបជញ្ជាំងផ្ទះ ការប្រើប្រាស់កំបោរសសម្រាប់រៀបចំស្រះ ត្រូវអនុវត្តដូចខាងក្រោម ៖

- សម្រាប់បាចនៅលើផ្ទៃបាតស្រះ ជារៀងរាល់ឆ្នាំ ក្រោយពេលស្តារភក់បាតស្រះ នៅក្នុងកំឡុងពេលរៀបចំស្រះ។
- ចំពោះស្រះ ថ្មីគួរប្រើកំបោរសពី ៣-៥ គ.ក្រ ក្នុង ១០០ម២។ ស្រះចាស់ពី ៥- ៨ គ.ក្រ ក្នុង១០០ម២
- បរិមាណកំបោរប្រែប្រួលទៅតាម pH (កំរិតជាតិជូរ) នៃដីស្រះ សូមមើលតារាងខាងក្រោម
- កំបោរសត្រូវលាយជាមួយទឹកក្នុងធុងដែក រួចយកឈើកូរឱ្យរលាយ ទើបយកទៅបាចសព្វពេញ ផ្ទៃស្រះ។ ត្រូវជៀសវាងការយកកំបោរសទៅលាយជាមួយទឹកក្នុងធុងជ័រ ដែលបណ្តាលឱ្យក្តៅ និងរលាយធុងជ័រនោះ ហើយគួរជៀសវាងការដកដង្ហើមស្រូបយកផ្សែង ឬ ម្សៅកំបោរស ។
- ក្រោយពីបាចកំបោរហើយ គួរទុកស្រះហាលថ្ងៃ រយៈពេលពី ២- ៣ ថ្ងៃ ។

| **កំរិត** | **ប្រភេទដី** | **បរិមាណកំបោរត្រូវប្រើ ( គ.ក្រ/១០០ម២)** |
|---|---|---|
| ៤- ៥ | អាស៊ីតខ្ពស់ | ២០ |
| ៥- ៦,៥ | អាស៊ីតមធ្យម | ១០ |
| ៦,៥- ៧,៥ | ធម្មតា | ៥ |
| ៧,៥- ៨,៥ | ជាតិបាស | ២ |
| ៨,៥- ៩,៥ | ជាតិបាស ខ្លាំង | ០ |

DRAFT




ការបាចកំបោរស លើផ្ទៃបាតស្រះ ចាស់ និង ថ្មី

- រួចបង្ហូរទឹកចូលក្នុងស្រះប្រមាណ ១ភាគ ៣ នៃបរិមាណទឹកសរុប ដោយឆ្លងកាត់តម្រង រួចទុកស្រះរយៈពេល ២- ៣ ថ្ងៃ។
- មានវិធីពីរយ៉ាងនៃការប្រើប្រាស់ជីធម្មជាតិ: វិធីទី ១- ដាក់ជីលាមកសត្វ ៤ បង្គី នៅគ្រប់ជ្រុងទាំង ៤ នៃស្រះ (បើជីលាមកមាន់ ដាក់តែ២ បង្គី) ក្នុងផ្ទៃស្រះ១០០ ម២ ហើយអាចបន្ថែមជីរុក្ខជាតិបៃតងខ្លះ ទៀតទៅក្នុងស្រះ រួចរង់ចាំរយៈពេល ២ - ៣ ថ្ងៃ ។
- វិធីទី ២- ដាក់លាមកសត្វ ឬ អាចដាក់បន្ថែមរុក្ខជាតិបៃតងទៅក្នុងស្រះតូចមួយ រួចទុករយៈពេលពី ៣-៥ថ្ងៃ ទើបទឹកក្នុងស្រះក្លាយជាទឹកជី ពេលនោះយើងអាចដួសទឹកនោះមកដាក់ចូលក្នុងស្រះចិញ្ចឹម ត្រីបាន ។ នេះជាវិធីមួយដ៏ល្អ ដែលយើងគួរយកមកអនុវត្ត ព្រោះវិធីនេះកាត់បន្ថយបាននូវការប្រើប្រាស់បរិមាណអុកស៊ីសែ្សន ពីក្នុងស្រះ ។
- បន្ទាប់មក កសិករអាចបង្ហូរទឹកចូលក្នុងស្រះឱ្យពេញល្មម តាមតម្រង និងត្រូវយកបន្ទះក្តារដាក់ទ្រពីក្រោមកម្លាំងទឹកហូរ ដើម្បីជៀសវាងការធ្វើឱ្យទឹកស្រះល្អក់ ។
- ក្នុងករណីទឹកស្រះមិនទាន់មានពណ៌បៃតងល្អ កសិករអាចលៃលកដាក់ជីបន្ថែមបន្តិចទៀត រហូតដល់ទឹកស្រះមានពណ៌បៃតងល្អ ។

នៅពេលទឹកស្រះមានពណ៌បៃតងល្អ នោះបញ្ជាក់ថា ទឹកស្រះនោះមានសម្បូរពពួកសត្វល្អិត ដែលហៅថាសត្វប្លង់តុង និងមានពពួករុក្ខជាតិថ្នាក់ទាប ដែលហៅថា រុក្ខជាតិប្លង់តុង ហើយវាជាចំណីធម្មជាតិយ៉ាងសំខាន់សម្រាប់ការរស់នៅរបស់ត្រី។ យើងអាចត្រួតពិនិត្យវត្តមាន សត្វប្លង់តុងបាន តាមរយៈការដួសទឹកពីជ្រុងម្ខាងនៃស្រះ ដោយ ប្រើក្រមា រួចយកកែវដួសទឹកចេញពីក្រមា ពេលនោះយើងនឹងសង្កេតឃើញ សត្វល្អិតតូចៗ នៅក្នុងកែវ ។

DRAFT


ការត្រួតពិនិត្យវត្តមានសត្វប្លង់តុងនៅក្នុងទឹកស្រះ


រូបភាពសត្វប្លង់តុងនៅក្នុងកែវ

ក្នុងករណីទឹកស្រះមិនទាន់មានពណ៌បៃតងល្អ កសិករអាចប្រើជីគីមីបន្ថែម ដូចជា ជី អ៊ុយរ៉េ និងជី ដេអាប៉េ (ដូចមានរូបភាពបង្ហាញ) ក្នុងកំរិតជី អ៊ុយរ៉េ ៣០០ ក្រាម និងជី ដេអាប៉េ ១០០ ក្រាម ក្នុងផ្ទៃទឹកស្រះ ១០០ម២ ។ ប៉ុន្តែយើងក៏អាចប្រើជីធម្មជាតិដូចបានរៀបរាប់ខាងលើ ។ នៅពេលទឹកស្រះមានពណ៌បៃតងហើយ យើងត្រូវបញ្ឈប់ ការប្រើប្រាស់ជីភ្លាម ។




ប្រភេទជីគីមី ដេអាប៉េ និងជី អ៊ុយរ៉េ




ការប្រើប្រាស់ជីគីមីនៅក្នុងស្រែចិញ្ចឹមត្រី ១០០ម២

## ២.៥.៣ - ការត្រួតពិនិត្យគុណភាពទឹក

**<u>ការវាស់វែងកំរិតថ្លានៃទឹកស្រែ</u>** យើងអាចប្រើថាសដែក ឬ ឈើ ដែលមានលាបពណ៌ស និងខ្មៅឆ្លាស់គ្នាដូចរូបភាពខាងក្រោមបានបញ្ជាក់ ដើម្បីធ្វើការវាស់ស្ទង់មើលកំរិតថ្លានៃទឹក។ ថាសដែក ឬ ឈើនោះ ជាទូទៅមានរាងមូល មានអង្កត់ផ្ចិតពី ២០ ទៅ ២៥ ស.ម ហើយត្រូវតភ្ជាប់ដោយដងឈើ ឬ ខ្សែ ដែលមានគំនូសក្រិតជាសង់ទីម៉ែត្រ ដើម្បីវាស់វែងកំពស់ទឹក។ យើងអាចធ្វើការវាស់ស្ទង់មើលកំរិតថ្លានៃទឹក ដោយដាក់ថាសដែក ឬ ឈើ នោះជ្រមុជទៅក្នុងទឹកបន្តិចម្តងៗ រហូតដល់ជម្រៅទឹក ដែលយើងនៅមើលឃើញពណ៌ស- ខ្មៅនៃថាសនោះ ។ បើសិនជាថាសដែកនោះនៅមើលឃើញក្នុងជម្រៅទឹក ៣០ ស.ម នោះបញ្ជាក់ថា ទឹកស្រែនោះមិនមានភាពល្អក់។ ផ្ទុយទៅវិញក្នុងករណីថាសដែកមិនអាចមើលឃើញភ្លាមៗ ពេលដាក់ចូលក្នុងទឹក នោះបញ្ជាក់ថា ទឹកស្រែនោះល្អក់ ឬ មានជីច្រើនពេក (ដែលភាគច្រើនមានពណ៌បៃតងខ្ចាំង) ។

DRAFT







ថាស **Secchi Disc** សម្រាប់វាស់គុណភាពទឹក និងក្រដាស **pH** សម្រាប់ វាស់កំរិតជាតិអាស៊ីតក្នុងទឹកស្រែ

<u>ការវាស់វែង</u>

**<u>ជាតិជូរ ឬ ជាតិអាស៊ីតនៃទឹកស្រែ</u>** យើងអាចធ្វើការវាស់វែងកំរិតជាតិអាស៊ីត ឬជាតិបាស នៃទឹកស្រែចិញ្ចឹមត្រី ដែលគេហៅថា pH ដោយប្រើក្រដាស pH ជ្រលក់ទៅក្នុងទឹកស្រែនោះ (ដូចរូបភាពខាងលើ) ឬ ម្យ៉ាងទៀត បើមានលទ្ធភាពគេប្រើម៉ាស៊ីនវាស់តែម្តង ។ ក្រោយពេលជ្រលក់ទៅក្នុងទឹករួច យើងយកវាមកផ្ទៀង លើ គំរូក្រដាស pH ដែលមាន

បញ្ជាក់ជាតួលេខ ។ បើ pH តូចជាង 7 នោះបញ្ជាក់ថា ទឹកស្រះនោះមានជាតិអាស៊ីត បើ pH តូចជាងឬស្មើ 5 ទឹកស្រះមានជាតិអាស៊ីតខ្លាំង ដែលធ្វើឱ្យត្រីពិបាករស់នៅ និងមិនអាចរីកធំធាត់បាន ។ ក្នុងករណីនេះ យើងអាចប្រើកំបោរដើម្បីកែលំអទឹកស្រះដែលមានជាតិអាស៊ីតមកត្រឹម pH = 6.5-8.5 បាន ។

### ២.៦- ការជ្រើសរើសកូនត្រីពូជដាក់ចិញ្ចឹម

ការជ្រើសរើសប្រភេទកូនត្រីពូជដាក់ចិញ្ចឹម មានសារៈប្រយោជន៍សំខាន់ណាស់ ក្នុងការចិញ្ចឹមត្រី ដើម្បីទទួលបានជោគជ័យ ដូចនេះត្រូវយកចិត្តទុកដាក់ដូចខាងក្រោមនេះ ៖

- ជាប្រភេទត្រីកសិករងាយស្រួលចិញ្ចឹម ដោយប្រើប្រាស់ចំណីធម្មជាតិដែលមានស្រាប់ក្នុងភូមិ ដូចជា ចក កណ្ដៀរ ជន្លេន កាកសំណល់បន្លែ ព្រមទាំងជីរុក្ខជាតិបៃតង និងជីលាមកសត្វ ។ ដូចនេះ កសិករមិនអាចចិញ្ចឹមប្រភេទត្រីស៊ីសាច់ជាអាហារទេ ព្រោះកសិករគ្មានទុនទិញចំណីសាច់ឱ្យត្រីចិញ្ចឹមដែលស៊ីសាច់ជាអាហារ ។
- ជាប្រភេទត្រីធន់នឹងជម្ងឺ
- ងាយស្រួលផលិតពូជ ក្នុងមជ្ឈដ្ឋានទឹកធម្មជាតិ
- កសិករ មានលទ្ធភាពចិញ្ចឹម

ប្រភេទត្រីដែលសមស្របសម្រាប់កសិករអាចចិញ្ចឹមបានមាន ត្រីទីឡាព្យ៉ា កាបសាមញ្ញ កាបស កាបឥណ្ឌា ឆ្ពិន និងត្រីកន្ធរជាដើម ។ លក្ខណៈពិសេសនៃប្រភេទត្រីទាំងនេះមានដូចក្នុងតារាងខាងក្រោម ៖

DRAFT

| រូបភាព | ឈ្មោះត្រី | លក្ខខណ្ឌសំខាន់ៗ | | | | ប្រភេទចំណី | ពេលវេលា(សប្តាហ៍) | | កំណត់សំគាល់ផ្សេងទៀត |
|---|---|---|---|---|---|---|---|---|---|
| | | អុកស៊ីសែន (mg/L) | សីតុណ្ហភាព ($^{O}$C) | កំហាប់អំបិល | pH | | ត្រីសាច់ | ត្រីពូជ | |
|  | ទីឡាព្យ៉ា | 2-3 | 14-40 | 30/1000 | 4-9 | បួង់តុង<br>កាកសំណល់បន្លែ<br>ចក<br>ជន្លេន<br>ចំណីសិប្បនិម្មិត | 25-32 | 20-25 | ប្រភេទត្រីក្រៅស្រុក<br>ងាយស្រួលពងកូនក្នុងធម្មជាតិ ក្នុងស្រះ<br>ទំងន់មេពូជៈ 100-200 ក្រាម<br>អាចផលិតពូជបានៈ 6-10 ដង / ឆ្នាំ<br>កម្លាំងបន្តពូជៈ 600- 1,000 គ្រាប់ពង/ ដង |
|  | កាបសាមញ្ញ | 3 | 20- 30 | 14/1000 | 6.5-8.5 | សត្វបួង់តុង<br>សត្វស្រទាប់បាត<br>កាកសំណល់បន្លែ<br>ចក<br>ចំណីសិប្បនិម្មិត | 40 ឡើង | 48-52 | ប្រភេទត្រីក្រៅស្រុក<br>បង្កាត់ ភ្ញាស់ក្នុងធម្មជាតិ និងអាងបង្កាត់<br>ទំងន់មេពូជៈ 300-1000 ក្រាម<br>រដូវបន្តពូជក្នុងខែ ឧសភា- សីហា<br>កម្លាំងបន្តពូជ = 10,000-20,000 គ្រាប់ពង / គ.ក្រ ត្រីមេ |
|  | កាបស | 5 | 25- 30 | 10/1000 | 6.5-8 | បួង់តុង<br>កាកសំណល់បន្លែ<br>ចំណីសិប្បនិម្មិត | 40 ឡើង | 96 - 104 | ប្រភេទត្រីក្រៅស្រុក<br>បង្កាត់ ភ្ញាស់ក្នុងអាងបង្កាត់<br>ទំងន់មេពូជៈ 1,000-1,500 ក្រាម<br>រដូវបន្តពូជក្នុងខែ ឧសភា- សីហា<br>កម្លាំងបន្តពូជ 40,000 គ្រាប់ពង /គ.ក្រ ត្រីមេ |

DRAFT

| រូបភាព | ឈ្មោះត្រី | លក្ខខណ្ឌសំខាន់ៗ | | | | ប្រភេទចំណី | ពេលវេលា(សប្តាហ៍) | | កំណត់សំគាល់ផ្សេងទៀត |
|---|---|---|---|---|---|---|---|---|---|
| | | អុកស៊ីសែន (mg/L) | សីតុណ្ហភាព ($^{O}C$) | កំហាប់ អំបិល | pH | | ត្រីសាច់ | ត្រីពូជ | |
|  | កាបឥណ្ឌា | 5 | 25- 30 | 10/1000 | 6.5- 8, | ប្លង់តុង<br>សត្វប្លង់តុង<br>ចំណីសិប្បនិម្មិត | 40 ឡើង | 96 - 104 | ប្រភេទត្រីក្រៅស្រុក<br>បង្កាត់ ភ្ញាស់ក្នុងអាងបង្កាត់<br>ទំងន់មេពូជៈ 1,000-1,500 ក្រាម<br>រដូវបន្តពូជក្នុងខែ ឧសភា- សីហា<br>កម្លាំងបន្តពូជៈ 40,000 គ្រាប់ពង/គ.ក្រ ត្រីមេ |
|  | ឆ្ពិន | 5 | 25- 30 | 7/1000 | 6.5- 7.5 | ប្លង់តុង<br>កាកសំណល់បន្លែ<br>ចក<br>ចំណីសិប្បនិម្មិត | 40 ឡើង | 48-52 | ជាប្រភេទត្រីក្នុងស្រុក<br>បង្កាត់ ភ្ញាស់ក្នុងធម្មជាតិ និងអាងបង្កាត់<br>មេពូជមានទំងន់ពី ២០០- ៨០០ ក្រាម<br>រដូវបន្តពូជក្នុងខែ ឧសភា ដល់ កក្កដា<br>កម្លាំងបន្តពូជៈ ៦០០.០០០គ្រាប់ពង/គ.ក្រ ត្រីមេ |

DRAFT

## ២.៧- ការដឹកជញ្ជូនកូនត្រី

ការយកចិត្តទុកដាក់ក្នុងការដឹកជញ្ជូនកូនត្រីពីកន្លែងបង្កាត់ ភ្ញាស់ ឬ លក់កូនត្រី ទៅដាក់ចិញ្ចឹមក្នុងស្រះមានសារៈសំខាន់ណាស់ ដើម្បីជៀសវាងកូនត្រីងាប់ក្នុងរយៈពេលដឹកជញ្ជូន និង ក្រោយពេលដាក់ចិញ្ចឹម ។ ខាងក្រោមនេះជាលក្ខណៈបច្ចេកទេសសំខាន់ៗ នៃការដឹកជញ្ជូនកូនត្រីៈ

ស្រះដែលត្រូវដាក់កូនត្រីចិញ្ចឹម ត្រូវរៀបចំឱ្យបានល្អតាមលក្ខណៈបច្ចេកទេសរៀបចំស្រះ ដែលបានរៀប រាប់ខាងលើ ។

- កូនត្រីដែលត្រូវដឹកជញ្ជូន ត្រូវរៀបចំដាក់ក្នុងហាប៉ាឱ្យបានមុន ១ថ្ងៃ នៃការដឹកជញ្ជូន និងមិនត្រូវផ្តល់ចំណី
- កូនត្រីដែលត្រូវចាប់ពីស្រះ ដាក់ក្នុងហាប៉ា ត្រូវជៀសវាងអូសចាប់នៅពេលយប់ ព្រោះកូនត្រីអាចពុលងាប់ដោយសារអុកស៊ីសែ្សនក្នុងស្រះនៅពេលយប់មានកំរិតតិចតួចបំផុត ។
- ក្នុងករណីដឹកជញ្ជូនផ្លូវឆ្ងាយ ត្រូវរៀបចំថង់ប្លាស្ទិក ដែលមានទំហំ ៦០ x ៨០ ស.ម និង ត្រូវមានខ្យល់ អុកស៊ីសែនសម្រាប់បញ្ចូលក្នុងថង់កូនត្រី ។ ក្នុងករណីខ្លះ យើងអាចប្រើអំបិល ឬ មេទីឡែនពណ៌ខៀវ ក្នុងកំរិតតែ ២ក្រាម ក្នុង១លីត្រទឹក ដើម្បីសម្លាប់មេរោគ និងបាក់តេរី ដែលអាចមានក្នុងថង់កូនត្រី ។
- កូនត្រីដែលមានទំហំ ៥ ស.ម អាចដាក់ក្នុងថង់ទំហំខាងលើ ប្រមាណពី ៣០០- ៥០០ ក្បាល អាស្រ័យទៅនឹងចំងាយផ្លូវដែលត្រូវដឹកជញ្ជូនជាក់ស្តែង ។
- បើដឹកជញ្ជូនផ្លូវជិតៗ យើងអាចប្រើធុង ឆ្នាំង ឬ សម្ភារៈផ្សេងៗទៀត ដែលអាចដឹកជញ្ជូនបាន តែត្រូវឱ្យស្អាត គ្មានជាតិពុល ។
- ទឹកដែលត្រូវដាក់ក្នុងថង់ ឬ ធុងកូនត្រីដឹកជញ្ជូន ត្រូវយកចេញពីស្រះដែលកូនត្រីរស់នៅ
- គួរដឹកជញ្ជូនកូនត្រីនៅពេលព្រឹក ព្រោះអាកាសធាតុនៅត្រជាក់ល្អ
- ក្នុងករណីដឹកជញ្ជូនតាមកង់ ឬ ម៉ូតូ ត្រូវធ្វើយ៉ាងណាកុំឱ្យកូនត្រីត្រូវកំដៅថ្ងៃខ្លាំង ។

DRAFT




របៀបដឹកជញ្ជូនកូនត្រីក្នុងចម្ងាយផ្លូវជិតៗ ដោយប្រើធុង ឆ្នាំង ឬ សម្ភារៈស្អាតល្អផ្សេងៗទៀត



ក្នុងករណីដឹកជញ្ជូនកូនត្រីផ្លូវឆ្ងាយ ត្រូវប្រើថង់ប្លាស្ទិក និងត្រូវបំពេញដោយខ្យល់អុកស៊ីសែន

## ២.៨- ការដាក់កូនត្រីចិញ្ចឹម

ស្រះអាចដាក់កូនត្រីចិញ្ចឹមបាន នៅពេលស្រះមានទឹកគ្រប់គ្រាន់ ជាធម្មតាមាននៅពេលរដូវភ្លៀងធ្លាក់។ បើសិនរដូវភ្លៀងពន្យាពេល ឬ មិនធ្លាក់ភ្លៀងនៅដើមឆ្នាំ កសិករក៏អាចដាក់ចិញ្ចឹមត្រីបានដែរ រហូតដល់ខែ កញ្ញា តុលា ហើយប្រមូលផលនៅរដូវប្រាំង ពេលទឹកស្រះស្រកជិតអស់។ ប៉ុន្តែបរិមាណផលត្រីចិញ្ចឹមបានមក តិចជាងផលត្រីដែលត្រូវដាក់ចិញ្ចឹមនៅដើមរដូវភ្លៀងធ្លាក់ ។

- មុនដាក់កូនត្រីចិញ្ចឹមក្នុងស្រះ ត្រូវត្រួតពិនិត្យមើលស្រះ និងទឹកស្រះនោះត្រូវបានរៀបចំល្អហើយ ដូចចំណុចមេរៀនទី ២.៥ បានបញ្ជាក់។
- កូនត្រីដាក់ចិញ្ចឹមត្រូវមានទំហំធំ យ៉ាងហោចណាស់ទំហំ ៥ ស.ម និងមានសុខភាពល្អ ដោយសំគាល់ថា កូនត្រីមានដងខ្លួនស្អាតល្អ មានសកម្មភាពហែលរហ័សរហួន ។
- កុំលែងកូនត្រីចូលក្នុងស្រះភ្លាម ត្រូវត្រាំថង់កូនត្រីក្នុងទឹកស្រះនោះឱ្យបានរយៈពេល ៥នាទីសិនដើម្បី ឱ្យសីតុណ្ហភាពទឹកក្នុងថង់ដូចសីតុណ្ហភាពទឹកក្នុងស្រះបន្ទាប់មកទើបស្រាយមាត់ថង់កូនត្រីលែងចូលស្រះបន្តិចម្តងៗ
- ត្រូវលែងកូនត្រីចូលស្រះនៅពេលថ្ងៃ ព្រោះនៅពេលថ្ងៃក្នុងទឹកស្រះសម្បូរខ្យល់អុកស៊ីសែន
- មិនត្រូវលែងកូនត្រីនៅពេលមេឃកំពុងភ្លៀងខ្លាំង ព្រោះពេលនោះ pH ថយចុះ
- ក្រោយពីលែងកូនត្រីហើយ មិនត្រូវប្រើកំបោរចូលក្នុងស្រះកំពុងចិញ្ចឹមត្រី ហើយត្រូវការពារស្រះកុំ ឱ្យល្អក់ទឹក និងកុំឱ្យមានថ្នាំពុលផ្សេងៗមកចូលក្នុងស្រះត្រី ។
- ម្យ៉ាងទៀត កសិករគួរខុស្សាហ៍ធ្វើការត្រួតពិនិត្យមើលស្រះចិញ្ចឹមត្រី ឱ្យបានរៀងរាល់ថ្ងៃ ដើម្បីឃ្លាំមើលសុខភាពត្រី ត្រីងាប់ ។ល។

DRAFT



សកម្មភាពត្រាំថង់កូនត្រីក្នុងទឹកស្រះ មុនពេលលែងចូលស្រះចិញ្ចឹម

សម្រាប់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ចំនួនកូនត្រីដែលត្រូវដាក់ចិញ្ចឹមក្នុង ១ ម៉ែត្រការេស្រះ គឺមានតែ ៣ ទៅ ៤ ក្បាល ប៉ុណ្ណោះ ហើយអាចទទួលផលត្រីបានពី ៣០ ទៅ ៤០ គ.ក្រ/ ១០០ម២ ស្រះ ក្នុងរយៈពេលចិញ្ចឹម ៨ ខែ ប្រសិនបើការចិញ្ចឹមគ្រប់គ្រងបានល្អ ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ គួរកត់សំគាល់ថា:

**ចំនួនកូនត្រីដាក់ចិញ្ចឹមត្រឹមត្រូវក្នុង១ម$^{២}$ = កូនត្រីលូតលាស់បានល្អ**

**ចំនួនកូនត្រីដាក់ចិញ្ចឹមច្រើនពេកក្នុង ១ម$^{២}$= កូនត្រីលូតលាស់មិនបានល្អ**

ក្នុងករណីកូនត្រីដែលត្រូវដាក់ចិញ្ចឹមមានទំហំតូច យើងត្រូវបំប៉នវានៅក្នុងហាប៉ាររហូតបានទំហំ ៥ស.ម ទើបអាចលែងវាចូលក្នុងស្រះចិញ្ចឹមបាន។

ខាងក្រោមនេះ ជាភាគរយនៃប្រភេទត្រីនីមួយៗ ដែលអាចដាក់ចិញ្ចឹមចម្រុះចូលគ្នាបាន ក្នុងស្រះចិញ្ចឹម តែមួយ ដោយផ្អែកលើលក្ខណៈជីវសាស្ត្រនៃប្រភេទត្រីនីមួយៗ ចរិករស់នៅ ស៊ីចំណី លក្ខណៈបន្តពូជ តម្រូវការ ទីផ្សារ ប្រភេទត្រីដែលអាចរកទិញដាក់ចិញ្ចឹមបាន និងអាស្រ័យទៅលើសមត្ថភាព និង លទ្ធភាពរបស់កសិករម្នាក់ៗ

| **លទ្ធភាពដាក់ចិញ្ចឹមតាមប្រភេទ** | **ទីឡាព្យ៉ា** | **កាបស** | **កាបឥណ្ឌា** | **កាបសាមញ្ញ** | **ឆ្ពិន** |
|---|---|---|---|---|---|
| ដាក់ចិញ្ចឹម ៥ ប្រភេទ | ៤០% | ២០% | ១០% | ១០% | ២០% |
| ដាក់ចិញ្ចឹម ៣ ប្រភេទ | ៥០% | ២០% | | | ៣០% |
| ដាក់ចិញ្ចឹម ៣ ប្រភេទ | ៥០% | ៣០% | ២០% | | |
| ដាក់ចិញ្ចឹម ៣ ប្រភេទ | ៥០% | ៤០% | | ១០% | |
| ដាក់ចិញ្ចឹម ៣ ប្រភេទ | ៥០% | | | ១០% | ៤០% |

DRAFT

## ២.៩- ប្រភេទចំណី និងរបៀបដាក់ចំណី

ចំណីត្រីមានពីរប្រភេទ គឺ ចំណីធម្មជាតិ និងចំណីបន្ថែម ។ ចំណីធម្មជាតិជាចំណីសំខាន់សម្រាប់ត្រី ដូចជា សត្វល្អិតតូចៗ និងរុក្ខជាតិល្អិតតូចៗ ដែលកើតឡើងពីការដាក់ជីទៅក្នុងស្រះចិញ្ចឹមត្រី តាមរបៀបដូចបានរៀបរាប់ខាងលើ។ ចំណីបន្ថែមមានពីរប្រភេទ គឺចំណីរស់ និងចំណីសិប្បនិម្មិត ដែលអាចផ្តល់ឱ្យត្រីស៊ីបន្ថែម ដើម្បីបង្កើនការលូតលាស់ របស់ត្រី ។ ចំណីរស់ក៏ជាប្រភេទចំណីធម្មជាតិដែរ មានដូចជា កណ្តៀរ ជន្លេន សត្វល្អិត ចកបាយទា។ ចំណីសិប្បនិម្មិត ជាការលាយផ្សំចំណីច្រើនប្រភេទចូលគ្នា ដូចជា កន្ទក់ ចុងអង្ករ ម្សៅត្រី ចំណីគ្រាប់ និងម្សៅគ ជាដើម ។ ដោយសារចំណីសិប្បនិម្មិតមានតម្លៃថ្លៃ ដូចនេះកសិករគួរប្រើសម្រាប់ថែបំប៉នកូនត្រី និងត្រីមេពូជ ។ ចំពោះកសិករ នៅតាមជនបទភាគច្រើនពុំមានលទ្ធភាពប្រើប្រាស់ចំណីសិប្បនិម្មិតឱ្យត្រីស៊ីទេ លើកលែងកសិករផលិតកូនត្រីពូជ ចាំបាច់ត្រូវប្រើប្រាស់ប្រភេទចំណីសិប្បនិម្មិត ដើម្បីថែបំប៉នកូនត្រីឱ្យឆាប់ធំ និងថែបំប៉នត្រីមេពូជឱ្យឆាប់ពេញវ័យបន្តពូជ ។ ខាងក្រោមនេះជាឧទាហរណ៍មួយនៃរបៀបលាយផ្សំចំណីសិប្បនិម្មិត សម្រាប់ប្រើក្នុងការថែបំប៉នៈ

| លរ | បរិយាយធាតុផ្សំចំណី | ភាគរយ | តម្លៃឯកត្តា | ផ្សេងៗ |
|---|---|---|---|---|
| | | (%) | (៛/គ.ក្រ) | |
| ១ | កន្ទក់ | ២០ | ៥៥០ | |
| ២ | ចុងអង្ករ | ១៥ | ៧០០ | |
| ៣ | ម្សៅត្រី | ២០ | ១៨០០ | |
| ៤ | ចំណីគ្រាប់ | ៣០ | ២២០០ | |
| ៥ | ម្សៅត | ១៥ | ៧០០ | អាចរកទិញបានពី ផ្សារដើមគ |
| | សរុប | ១០០ | | |

ខាងក្រោមនេះជារបៀបផ្សំចំណីសិប្បនិម្មិត សម្រាប់កសិករដែលមានទុនតិច អាចមានលទ្ធភាពប្រើប្រាស់បាន សម្រាប់ថៃបំប៉នកូនត្រីៈ

| លរ | បរិយាយធាតុផ្សំចំណី | បរិមាណ | តម្លៃ/ ឯកត្តា | ផ្សេងៗ |
|---|---|---|---|---|
| | | (កំប៉ុងទឹកដោះគោ) | (៛/ គ.ក្រ) | |
| ១ | ចុងអង្ករ | ៤ | ៧០០ | |
| ២ | កន្ទក់ | ១១ | ៥៥០ | |
| ៣ | ម្សៅត្រី | ៥ | ១៨០០ | |

ខាងក្រោមនេះជាគោលការណែនាំសំខាន់ៗ សម្រាប់ផ្តល់ចំណីត្រី ដើម្បីជាប្រយោជន៍ដល់កសិករៈ

- ត្រូវផ្តល់ចំណីត្រីឱ្យបានទៀងទាត់ពេលវេលា និងចំទីកន្លែងដែលធ្លាប់ផ្តល់ឱ្យ ដើម្បីងាយស្រួលដល់ត្រីដឹង ទីកន្លែងដែលផ្តល់ចំណីឱ្យស៊ី ។ ម្យ៉ាងទៀត កសិករអាចប្រើជាស៊ុមចំណី ងាយស្រួលសង្កេតមើលសកម្ម ភាពស៊ីចំណី និងការលូតលាស់របស់ត្រី ។
- ត្រូវផ្តល់ចំណីតាមកំរិតកំណត់ ជៀសវាងផ្តល់ចំណីច្រើនហួសកំរិត ដែលនាំឱ្យត្រីស៊ីមិនអស់ ខាតបង់ថវិកា ធ្វើឱ្យគុណភាពទឹកស្អុយ និងទឹកស្រះខ្វះខ្យល់អុកស៊ីសែ្សន ។
- បរិមាណចំណីដែលត្រូវផ្តល់ អាស្រ័យបទពិសោធន៍នៃការដាក់ចំណីត្រីប្រចាំថ្ងៃ។ ជាទូទៅ កូនត្រីត្រូវការបរិមាណចំណីតិចជាងត្រីធំ។ កសិករត្រូវចេះថ្លឹងថ្លែងដាក់ចំណីឱ្យត្រីស៊ីបន្តិចម្តងៗជារៀងរាល់ថ្ងៃ ។ ឧទាហរណ៍ ក្រោយពីការដាក់ចំណីហើយ ត្រីនៅតែហែលជុំវិញកន្លែងដាក់ចំណី នោះបញ្ជាក់ថា ត្រីត្រូវការស៊ីចំណីបន្ថែមទៀត ។
- កសិករខ្លះផ្តល់ចំណីត្រីតាមគោលការណ៍ណែនាំបច្ចេកទេស គឺពី ៥-១០% នៃទំងន់ដងខ្លួនសរុបត្រី ក្នុង១ថ្ងៃ
- កូនត្រីនៅតូចត្រូវការបរិមាណចំណីតិចជាងត្រីធំ ប៉ុន្តែវាត្រូវការចំណីមានគុណភាពប្រូតេអ៊ីនច្រើនជាង ត្រីធំ ដើម្បីពង្រឹងសុខភាព និងបង្កើនការលូតលាស់ឱ្យឆាប់រហ័ស ។

DRAFT

- ក្នុងករណីចំណីបន្ថែមត្រូវផ្ដល់ឱ្យត្រីស៊ី២ដងក្នុង១ថ្ងៃ គឺនៅពេលព្រឹក និងពេលរសៀល នៅក្នុងអំឡុងពេលមានពន្លឺថ្ងៃ។ ត្រូវជៀសវាងផ្ដល់ចំណីត្រីនៅពេលព្រឹកព្រលឹម ដែលពុំទាន់មានពន្លឺថ្ងៃគ្រប់គ្រាន់ ព្រោះពេលនោះក្នុងទឹកស្រះកំពុងខ្វះខ្យល់អុកស៊ីសែ្សន ។ ដូចនេះ ត្រូវផ្ដល់ចំណីត្រីនៅពេលមានពន្លឺថ្ងៃគ្រប់គ្រាន់ ដែលធ្វើឱ្យសម្បូរខ្យល់អុកស៊ីសែ្សននៅក្នុងទឹកស្រះ ហើយធ្វើឱ្យត្រីមិនពុល និងស៊ីចំណីបានច្រើន ។

## ២.១០- ប្រភេទជី និងរបៀបដាក់ជី

ការប្រើប្រាស់ជីក្នុងការចិញ្ចឹមត្រី មាន ២ ដំណាក់កាលផ្សេងគ្នា គឺនៅពេលរៀបចំស្រះម្ដង និងនៅពេលក្រោយដាក់ត្រីចិញ្ចឹមម្ដងទៀត។ ដូចបានរៀបរាប់ខាងលើពីផលប្រយោជន៍នៃការប្រើប្រាស់ជីនៅពេលរៀបចំស្រះ ដើម្បីធ្វើឱ្យទឹកស្រះមានពណ៌បៃតងល្អ សម្បូរខ្យល់អុកស៊ីសែ្សន និងមានចំណីធម្មជាតិគ្រប់គ្រាន់ ហើយពេលនោះកសិករអាចដាក់កូនត្រីចិញ្ចឹមបាន ។ ក្រោយពេលដាក់កូនត្រីហើយប្រមាណ ១សប្ដាហ៍ កសិករត្រូវសង្កេតមើលពណ៌ទឹកស្រះ ក្នុងករណីទឹកស្រះលែងមានពណ៌បៃតង កសិករត្រូវដាក់ជីបន្ថែម រហូតដល់ទឹកស្រះមានពណ៌បៃតងល្អ ។ ក្នុងករណីទឹក ស្រះមានពណ៌ល្អក់ កសិករត្រូវពិនិត្យមើលវត្ថុមានបរិមាណចំណីធម្មជាតិ ដោយប្រើក្រមាដួសមើលទឹកពីជ្រុងម្ខាង នៃស្រះ រួចយកកែវដួសទឹកចេញពីក្រមា ពេលនោះយើងនឹងសង្កេតឃើញពីវត្ថុមានសត្វល្អិតតូចៗ នៅក្នុងកែវ ។ បើ បរិមាណសត្វបួងតុងមានចំនួនតិច កសិករត្រូវបន្ថែមជី ។

ការប្រើប្រាស់ជីបន្ថែម ក្រោយពេលដាក់កូនត្រីចិញ្ចឹម មានអត្ថប្រយោជន៍មិនត្រឹមតែបង្កើនចំណីធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនបរិមាណខ្យល់អុកស៊ីសែ្សន កាត់បន្ថយបរិមាណឧស្ម័នពុលទៀតផង ។ បរិមាណជី ដែលប្រើប្រាស់បន្ថែមនេះមានបរិមាណតិចជាង បរិមាណជីប្រើពេលរៀបចំស្រះ ។ បើកសិករប្រើជីបន្ថែមមិនបានត្រឹមត្រូវនោះនឹងធ្វើឱ្យត្រីពុល និងអាចងាប់ឆាប់រហ័ស ។ ដូចបានរៀបរាប់ក្នុងមេរៀនរៀបចំស្រះ ប្រភេទជីត្រូវប្រើមាន ២ ប្រភេទគឺ ជីធម្មជាតិ ឬសរីរាង្គ (ជីលាមកសត្វ និងជីបៃតង) និងជីគីមី ឬជីអសរីរាង្គ (មានជីអ៊ុយរ៉េ និងជីដេអាប៉េ) ដែលជាប្រភេទជីគ្រាប់មានពណ៌ស និងពណ៌ខ្មៅ ។ ក្នុងករណីចង់ប្រើជីបន្ថែមជាប្រភេទជីគីមី កសិករត្រូវយកជីអ៊ុយរ៉េ ៣០០ ក្រាម លាយជាមួយជីដេអាប៉េ ១០០ ក្រាម កូរជាមួយទឹកក្នុងធុងឱ្យរលាយគ្រាប់អស់សិន ទើបយកទៅបាចលើ ផ្ទៃទឹកស្រះ ដើម្បីកុំឱ្យត្រីចាប់យកគ្រាប់ជីស៊ីផ្ទាល់ ដែលនឹងធ្វើឱ្យត្រីងាប់ភ្លាម ។ បើកសិករចង់ប្រើជីទាំងពីរប្រភេទចូល គ្នា ត្រូវប្រើក្នុងបរិមាណតិចតួចបំផុត គឺតិចជាងបរិមាណជីប្រើពេលរៀបចំស្រះ ដើម្បីជៀសវាងការប្រើជីជ្រុលហួស កំរិត ដែលធ្វើឱ្យទឹកស្រះពុល ខ្យល់អុកស៊ីសែ្សនក្នុងស្រះធ្លាក់ចុះ បរិមាណឧស្ម័នពុលកើនឡើង និងធ្វើឱ្យត្រីងាប់ភ្លាម ។ ចំពោះការប្រើជីធម្មជាតិ កសិករត្រូវអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម:

- ជីករណ្ដៅមួយមានទំហំបណ្ដោយ ២-៣ ម ទទឹង ១- ២ ម ជម្រៅ ០,៥ម ឬ ជីករណ្ដៅតូចមួយ នៅលើភ្លឺស្រះ(រូបខាងក្រោម) រួចដាក់លាមកសត្វគោ ក្របី ឬ ជ្រូក មាន់ ទា និង ឬ ស្លឹករុក្ខជាតិបៃតង ជីទន្រ្សែងខេត្ត ត្រាំទឹកក្នុងរណ្ដៅនោះ ។
- រួចទុករវាងរយៈពេលពី ៣ទៅ៥ថ្ងៃ បន្ទាប់មកកសិករអាចដួសទឹកជីក្នុងរណ្ដៅនោះដាក់ចូលក្នុងស្រះ ចិញ្ចឹមត្រី
- វិធីនេះកាត់បន្ថយបានការប្រើប្រាស់បរិមាណអុកស៊ីសែន បន្ថយជាតិឧស្ម័នពុលនៅក្នុងស្រះចិញ្ចឹមត្រី ។

DRAFT




វិធីសាស្ត្រសមស្របនៃការប្រើប្រាស់ជីធម្មជាតិបន្ថែម ក្នុងស្រះចិញ្ចឹមត្រី

ជាទូទៅការប្រើប្រាស់ជីបន្ថែម ក្រោយពេលដាក់ត្រីចិញ្ចឹម ត្រូវអនុវត្តនៅពេលមានពន្លឺថ្ងៃគ្រប់គ្រាន់ ព្រោះពេលនោះទឹកក្នុងស្រះសម្បូរខ្យល់អុកស៊ីសែ្សន ដែលធ្វើឱ្យត្រីមិនពុល ក្រោយពេលដាក់ជី ។

ប្រសិទ្ធភាពនៃការប្រើប្រាស់ជី គឺអាស្រ័យនឹងកត្តាដូចខាងក្រោម:

- សីតុណ្ហភាពទឹកក្នុងស្រះចិញ្ចឹមត្រីមានពី ២៥ - ៣០ អង្សារសេ
- pH ក្នុងទឹកស្រះមានពី ៦,៥ - ៩
- កំរិតរលាយអុកស៊ីសែ្សនមានយ៉ាងតិចពី ៣- ៧ មីលីក្រាម ក្នុង១ លីត្រទឹក
- ប្រភេទដីស្រះ ភាគច្រើនជាប្រភេទដីឥដ្ឋ
- លក្ខណៈស្រះ ធំទូលាយ មានទឹកច្រើន គ្មានដើមឈើជុំវិញស្រះ និងមានជើងទេរ ។

ខាងក្រោមនេះ ជាការប្រៀបធៀបកំរិតជាតិអាសូត ដែលមាននៅក្នុងជីលាមកសត្វផ្សេងៗគ្នា

DRAFT




| | លាមកមាន់ | លាមកជ្រូក | លាមកពពែ | លាមកគោ ក្របី |
|---|---|---|---|---|
| N (%) | 4.5 | 1.9 | 1.8 | 1.1 |
| P (%) | 1.8 | 1.5 | 0.4 | 0.3 |
| K (%) | 1.4 | 1.9 | 0.9 | 1.4 |

**ឯកសារយោង**

- Brooks & Maluwa (1997) for chicken & pig manure;
- Kerr (1999) for goat manure;
- Straaten (1999) for cattle manure.

## ២.១១- ការគ្រប់គ្រងស្រះ

ក្រោយការដាក់កូនត្រីចិញ្ចឹមហើយ ការគ្រប់គ្រងស្រះជាសកម្មភាពមួយយ៉ាងសំខាន់ ដែលកសិករត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានជោគជ័យ ។ ការគ្រប់គ្រងស្រះ រួមមានសកម្មភាពសំខាន់ៗ ដូចខាងក្រោមនេះ ៖

- ត្រូវយកចិត្តទុកដាក់ក្នុងការដាក់ចំណីត្រី និងដាក់ជីបន្ថែមឱ្យបានទៀងទាត់ពេលវេលា (ដូចបានបញ្ជាក់ ក្នុងមេរៀនខាងលើ)
- ត្រូវគ្រប់គ្រងលក្ខខណ្ឌទឹកស្រះ ឱ្យបានល្អជាប់ជានិច្ច និងត្រូវត្រួតពិនិត្យគុណភាពទឹកស្រះជាប់ជាប្រចាំ
- ក្នុងករណីស្រះចិញ្ចឹមត្រីទីឡាព្យ៉ា ត្រូវឧស្សាហ៍ដួសកូនត្រីទីឡាព្យ៉ាមកបំប៉នក្នុងហាប៉ា
- ត្រូវយកចិត្តទុកដាក់ រកមូលហេតុនៃបញ្ហាកើតមានឡើង និងព្យាយាមដោះស្រាយបញ្ហា
- ត្រូវឧស្សាហ៍អង្កេតមើលសកម្មភាពត្រី ក្រែងលោកើតមានជម្ងឺ ត្រូវយកចិត្តទុកដាក់ការពារ កុំឱ្យត្រីកើតមានជម្ងឺ ។

### ២.១១.១ - ការត្រួតពិនិត្យគុណភាពទឹកស្រះ

ខ្យល់អុកស៊ីសែន សីតុណ្ហភាព និង pH (កំរិតជាតិជូរនៃទឹក) គឺជាកត្តាយ៉ាងសំខាន់ក្នុងការកំណត់លក្ខខណ្ឌនៃទឹកស្រះ ។ ខាងក្រោមនេះ ជាការពិពណ៌នាលំអិតអំពីកត្តាសំខាន់នីមួយៗ ទាំងនេះ ។

DRAFT

កំរិតជាតិជូរនៃទឹកស្រះ   pH

pH ជាកំរិតជាតិជូរ និងបាសនៃទឹកស្រះ ដែលមានរង្វាស់ពី 0 ដល់ ១៤។ បើ pH ស្រះមានពី 0 ដល់ជិតលេខ ៧ នោះទឹកស្រះមានជាតិអាស៊ីត ។ បើ pH ស្មើត្រឹមលេខ ៧ នោះទឹកស្រះគ្មានជាតិជូរ និងគ្មានជាតិបាស គេហៅថា ណឺត ។ បើ pH មានឡើងពីលេខ ៧ ដល់លេខ ១៤ មានន័យថាទឹកស្រះមានជាតិបាស ។ ជាទូទៅ ត្រីរស់នៅបានស្រួល និងមានការលូតលាស់ល្អ ក្នុងកំរិត pH មានពី ៦,៥ ដល់ ៨ ។ ត្រីឆាប់ទទួលភាពរំញោច ឬជម្ងឺ នៅពេលជួបលក្ខខណ្ឌទឹកមិនល្អ ដូចជារស់នៅក្នុងទឹកស្រះ ដែលមាន pH ទាប។ ត្រីភាគច្រើន ចាប់ផ្តើមទទួលជម្ងឺ និង ងាប់នៅពេលជួបលក្ខខណ្ឌទឹក ដែលមានកំរិត pH ទាបជាង៥ ក្នុងរយៈពេលយូរ ។ ពេលខ្លះកំរិត pH ក្នុងទឹកស្រះមាន ការប្រែប្រួលឆាប់រហ័ស ដូចជានៅពេលមានភ្លៀងធ្លាក់ច្រើន ដែលបង្កើតឱ្យមានជាតិអាស៊ីតនៅក្នុងទឹកស្រះ ។

កសិករអាចប៉ាន់ស្មានកំរិត pH ក្នុងទឹកស្រះ ដោយការភ្លក់ បើទឹកស្រះមានជាតិជូរ នោះមានន័យថា ទឹកស្រះមានជាតិអាស៊ីត ។ ម្យ៉ាងទៀត យើងអាចដឹងកំរិតជាតិអាស៊ីត ដោយការអង្កេតមើលប្រភពទឹកស្រះដែលយកមកប្រើ ។ ឧទាហរណ៍ ប្រភពទឹកមកពីវាលភក់ ឬ វាលល្បាប់ ឬ ពីទឹកន្លែងដទៃទៀត ដែលកខ្វក់សម្បូរទៅដោយ សារធាតុរលួយ ភាគច្រើនប្រភពទឹកទាំងនេះអាចមានជាតិអាស៊ីត ។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើនទឹកស្រះ ចិញ្ចឹមត្រីមានកំរិត pH ល្អ ក្នុងចន្លោះពី ៦,៥ ដល់ ៨ ។



DRAFT

**ការកំណត់បង្ហាញលក្ខខណ្ឌទឹកដែលល្អ សម្រាប់ការចិញ្ចឹមត្រី និងផលិតកូនត្រីពូជ**

## ២.១១.២ - កត្តាត្រូវត្រួតពិនិត្យគុណភាពទឹក

| លរ | ចំនុចសំខាន់ៗ ដែលត្រូវត្រួតពិនិត្យ | ចន្លោះលក្ខខណ្ឌទឹក ដែលល្អ | លក្ខណៈសំគាល់ លក្ខខណ្ឌទឹកមិនល្អ | អាចដោះស្រាយតាមវិធី |
|---|---|---|---|---|
| ១ | កំរិតកំពស់ទឹកស្រះ ឬ ជម្រៅទឹកស្រះ | 1- 2 ម៉ែត្រ | -មានត្រីច្រើនពេកក្នុងស្រះមានទឹកតិចជាង ៥0% | -ត្រូវបន្ថែមទឹកថ្មី ល្អ ចូលស្រះ<br>-កសិករអាចវាស់ស្ទង់មើលជម្រៅទឹកស្រះបាន<br>- ចាប់ត្រីខ្លះចេញពីស្រះ |
| ២ | កំរិតរលាយអុកស៊ីសែ្សន | ធំជាង 5 មីលីក្រាម ក្នុង ១ លីត្រទឹក (ppm) | -ត្រីងើបឡើងពេញផ្ទៃទឹក ទោះបីមានថ្ងៃរះហើយក៏ដោយ | -ទឹកស្រះត្រូវមានពណ៌បៃតងជានិច្ច<br>-អាចដូរទឹកស្រះចាស់ចេញខ្លះ ឬទាំងអស់ ដាក់ទឹកថ្មី ល្អស្អាតចូលវិញ<br>-មើលចំនុចមេរៀន ៤.១ និង ៤.២ |
| ៣ | pH | 6.5 ដល់ 8.0 | ប្រភពទឹកមកពីកន្លែងទឹកស្អុយមាន សារធាតុរលួយ ឬ មកពីកន្លែងដទៃ ទៀតដែលដឹងថាមានជាតិអាស៊ីត<br>-ដាក់ត្រីចិញ្ចឹមខ្លះក្នុងស្រះទឹកនោះដើម្បីសង្កេតមើលការរស់នៅរបស់ត្រីក្នុងទឹកស្រះនោះ<br>-ឬ ប្រើក្រដាស pH ដើម្បីវាស់បើអាចធ្វើបាន | -ដាក់កំបោរ៥ គ.ក្រ/១០០ម២ ស្រះក្នុងពេលរៀបចំស្រះរួចវាស់កំរិត pH ដោយប្រើក្រដាស pH |
| ៤ | សីតុណ្ហភាព | 25 ដល់ 30°C | -សីតុណ្ហភាពបរិយាកាសក្តៅ (ធំជាង 38°C) អាកាសធាតុប្រទេសកម្ពុជាមិនធ្លាប់មានខ្ពស់ជាង 38°C និងកម្រទាបជាង 25°C | -កសិករអាចប្រើទែម៉ូម៉ែត្រ ព្រោះមានតម្លៃថោក<br>-ប្តូរទឹកស្រះចេញខ្លះរួចបញ្ចូលទឹកថ្មីល្អស្អាត ដែលមានសីតុណ្ហភាពសមស្របពី 25 ទៅ 30°C<br>-កាត់បន្ថយបរិមាណត្រីដាក់ចិញ្ចឹម |
| ៥ | ទឹកល្អក់ | 1,300 មីលីក្រាមក្នុង១លីត្រទឹក | -ទឹកល្អក់ខ្លាំង មិនអាចមើលឃើញប្រើថាសដែកក្នុងជម្រៅទឹកពី ៥-១០ ស.ម | -ប្រើកំបោរពី៥-១០គ.ក្រ/១០០ម២ ស្រះ មុនពេលដាក់កូនត្រីចិញ្ចឹម |
| ៦ | ឧស្ម័នកាបូនិច | តិចជាង 50 មីលីក្រាម ក្នុង១ លីត្រទឹក | -ត្រីងើបឡើងពេញផ្ទៃទឹក ទោះបីមានថ្ងៃរះហើយក៏ដោយ | -ទឹកស្រះត្រូវមានពណ៌បៃតងជានិច្ច<br>-អាចដូរទឹកស្រះចាស់ចេញខ្លះ ឬទាំងអស់ ដាក់ទឹកថ្មី ល្អស្អាតចូលវិញ<br>-មើលចំនុចមេរៀន ៤.១ និង ៤.២ |
| ៧ | អាម៉ូញ៉ាក់ | តិចជាង 0.02 ទៅ 0.05 មីលីក្រាម ក្នុង១លីត្រទឹក | -ត្រីងើបឡើងពេញផ្ទៃទឹក ទោះបីមានថ្ងៃរះហើយក៏ដោយ | -ទឹកស្រះត្រូវមានពណ៌បៃតងជានិច្ច<br>-អាចដូរទឹកស្រះចាស់ចេញខ្លះ ឬទាំងអស់ ដាក់ទឹកថ្មី ល្អស្អាតចូលវិញ<br>-មើលចំនុចមេរៀន ៤.១ និង ៤.២ |

### ២.១១.៣ - ការត្រួតពិនិត្យ កូនត្រីពូជទីឡាព្យ៉ា

កសិករដែលចិញ្ចឹមត្រីទទួលបានជោគជ័យ ក៏មានសមត្ថភាពផលិតកូនត្រីទីឡាព្យ៉ាពីស្រះចិញ្ចឹមត្រីតាម លក្ខណៈធម្មជាតិផងដែរ ។ ប្រភេទត្រីទីឡាព្យ៉ា បន្តពូជក្នុងស្រះធម្មជាតិ នៅពេលវាមានអាយុពី ៥ ទៅ ៦ ខែ ។ ក្នុងករណីស្រះចិញ្ចឹមត្រីរៀបចំបានល្អ មានជើងទេរ និងមានលក្ខខណ្ឌទឹកល្អ ក្រោយពេលដាក់កូនត្រីចិញ្ចឹមរយៈពេលពី ៤ ទៅ ៥ ខែ ត្រីទីឡាព្យ៉ាចាប់ផ្តើមបន្តពូជក្នុងស្រះ តាមលក្ខខណ្ឌធម្មជាតិ ដោយមិនចាំបាច់ប្រើថ្នាំចាក់ (អ័រម៉ូន) ។ នៅពេលត្រីទីឡាព្យ៉ាក្លាយជាមេពូជល្អ វាអាចបន្តពូជបានពី ៦ ទៅ ១០ ដង ក្នុងមួយឆ្នាំ ។

ក្រោយពេលចិញ្ចឹមត្រីទីឡាព្យ៉ាបាន ៤ ទៅ ៥ ខែ កសិករត្រូវយកចិត្តទុកដាក់សង្កេតមើលលើផ្ទៃទឹក គ្រប់ជ្រុងទាំង៤ នៃស្រះ នៅរៀងរាល់ពេលព្រឹកព្រលឹម ។ នៅពេលនោះ យើងអាចសង្កេតឃើញមានកូនត្រីទីឡាព្យ៉ តូចៗ កំពុងហែលនៅលើផ្ទៃទឹកក្បែរជ្រុងស្រះ និងមានត្រីមេទីឡាព្យ៉ានៅក្បែរនោះ ដើម្បីការពារកូនរបស់វា ។ កសិករ អាចចាប់កូនត្រីនេះមកបំប៉នក្នុងហាប៉ា ដោយប្រើថ្នងដួសចាប់កូនត្រី (មើលរូបភាពខាងក្រោម) នៅរៀងរាល់ ៣ ទៅ ៤ ដង ក្នុងមួយខែ ។


ការចាប់កូនត្រីទីឡាព្យ៉ាពីស្រះ ដោយប្រើថ្នង


មកដាក់បំប៉នក្នុងស្រះចិញ្ចឹមត្រី

### ២.១១.៤ - ការព្យាយាមត្រួតពិនិត្យមើលស្រះចិញ្ចឹមត្រី

ការចិញ្ចឹមត្រីជានិច្ចកាលត្រូវឧស្សាហ៍ត្រួតពិនិត្យមើលមជ្ឈដ្ឋានជុំវិញស្រះ កុំឱ្យមានរូង ឬ រន្ធផ្សេងៗ ដែលអាចមានកណ្តុរ កង្កែប ឬ ពស់រស់នៅ វានឹងស៊ីកូនត្រីក្នុងស្រះ ។ ម្យ៉ាងទៀត ត្រូវព្យាយាមចាប់ត្រីកាចចេញពីស្រះឱ្យអស់ ដើម្បីកុំឱ្យវាស៊ីកូនត្រី ។ ក្រៅពីនេះ កសិករគួរធ្វើរបងព័ទ្ធជុំវិញស្រះ ការពារក្មេងធ្លាក់ចូលស្រះ និងសត្វពាហនៈផ្សេងៗ ចូលមកស៊ីស្មៅ ឬ ជាន់ភ្លឺស្រះខូច ។ ត្រូវព្យាយាមត្រួតពិនិត្យមើលសកម្មភាពត្រីក្នុងស្រះ ក្នុងករណីមានត្រី ណាមួយមានសុខភាពមិនល្អ ដូចជា មានស្នាមរបួស ដំបៅ ឬ ឈឺ ឬមានត្រីងាប់ ត្រូវចាប់វាចេញពីស្រះភ្លាម ដើម្បីកុំ ឱ្យឆ្លងទៅត្រីផ្សេងទៀត ។ ត្រូវព្យាយាមដាំស្មៅ និងថែរក្សាស្មៅនៅលើភ្លឺស្រះឱ្យបានល្អ ដើម្បីការពារការហូរច្រោះដី នាំឱ្យទឹកស្រះល្អក់ នៅពេលមានភ្លៀងធ្លាក់ ។ ម្យ៉ាងទៀត កុំគប្បីឱ្យមានរុក្ខជាតិទឹកដុះច្រើនគ្របដណ្តប់ពេញផ្ទៃស្រះ ដែលនាំរំខានដល់ការធ្វើរស្មីសំយោគរបស់រុក្ខជាតិបួង់តុង ។

### ២.១១.៥ - វិធានការការពារជម្ងឺត្រី

ជោគជ័យនៃការគ្រប់គ្រងលើសុខភាពត្រីចាប់ផ្តើម ពីការការពារកុំឱ្យមាន ជម្ងឺត្រី ប្រសើរជាងការព្យាបាលជម្ងឺ ។

ដើម្បីការពារកុំឱ្យមាន ជម្ងឺត្រី ត្រូវយកចិត្តទុកដាក់វិធានការការពារមួយចំនួន ដូចខាងក្រោមនេះ ៖

- ជ្រើសរើសប្រភេទត្រីដាក់ចិញ្ចឹមណា ដែលធន់នឹងជម្ងឺ និងមានសុខភាពរឹងមាំ និងអាចស៊ូទ្រាំនឹងការបំរែ បំរួល សីតុណ្ហភាព
- ជាកូនត្រីពូជ ផលិតចេញពីមេ បា ពូជល្អ
- កូនត្រីពូជត្រូវបានថែបំប៉នល្អត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- កូនត្រីត្រូវដាក់ចិញ្ចឹមក្នុងកំរិតដង់ស៊ីតេត្រឹមត្រូវតាមបច្ចេកទេស
- ស្រះដែលដាក់កូនត្រីចិញ្ចឹម ត្រូវបានរៀបចំល្អ ស្អាតតាមបច្ចេកទេស
- ត្រូវផ្តល់ចំណីគ្រប់គ្រាន់មានគុណភាពល្អ និងទៀងទាត់ពេលវេលា (ចំណីត្រូវពិនិត្យកុំឱ្យមានជាតិពុល)
- ប្រភពទឹកយកមកចិញ្ចឹម គ្មានជាតិពុល និងត្រូវគ្រប់គ្រងស្រះទឹកឱ្យបានល្អជាប់ជានិច្ច ។
- ត្រូវរៀបចំដឹកជញ្ជូនកូនត្រី ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស

ទាំងអស់នេះជាមូលដ្ឋានគ្រឹះនៃការការពារ ជម្ងឺត្រីកុំឱ្យកើតមាន ក្នុងអំឡុងពេលចិញ្ចឹមត្រី ។

ជម្ងឺ ត្រីភាគច្រើនកើតមានក្នុងរដូវភ្លៀង ឬ រដូវត្រជាក់ ។ ពេលជួបប្រទះនឹងជម្ងឺ កសិករភាគច្រើនអនុវត្ត ការព្យាបាលតាមវិធីសាស្ត្របុរាណ ដូចជា ការប្រើកំបោរ ជាមួយប៉ូតាស្យូមប៉ែម៉ង់កាណាត ឬ ប្រើជាមួយអំបិល ជាដើម ។

### ២.១២- ការប្រមូលផលត្រី

កសិករចិញ្ចឹមត្រីនៅតាមជនបទភាគច្រើន មានការប្រមូលផលត្រី ២ ដំណាក់កាលផ្សេងៗគ្នា គឺការប្រមូល ផលបណ្តើរៗ និងការប្រមូលផលទាំងស្រុង ។ ការប្រមូលផលបណ្តើរៗ គឺជាការប្រមូលផលត្រីបន្តិចបន្តួច ដែលអាច ចាប់ផ្តើម ក្រោយពេលចិញ្ចឹមបានរយៈពេល ៤ ទៅ ៥ខែ សម្រាប់បម្រើការហូបប្រចាំថ្ងៃតែប៉ុណ្ណោះ ហើយជាទូទៅកសិករ ច្រើនប្រើសន្ទូចបបក់ សន្ទូចរនោង មង ឬសំណាញ់ ជាដើម ។



ចំណែកការប្រមូលផលទាំងស្រុង កសិករច្រើនធ្វើឡើងក្នុងរដូវប្រាំង នៅពេលទឹកស្រះរបស់គាត់ជិតរីងអស់ ។ ជាធម្មតា កសិករច្រើនអនុវត្តនៅក្នុងអំឡុងខែ មីនា ឬ ខែមេសា ដែលជាពេលវេលាដ៏សមស្របមួយសម្រាប់កសិករចាប់ត្រីទាំងអស់លក់ទៅទីផ្សារ ព្រោះពេលនោះត្រីនៅទីផ្សារមានតម្លៃថ្លៃ។ ដើម្បីឱ្យត្រីរស់បានយូរ និងលក់បានតម្លៃថ្លៃ ក្រោយពេលប្រមូលផលហើយ កសិករគួរកុំដាក់ចំណីបន្ថែមឱ្យត្រីស៊ីមួយថ្ងៃមុនពេលប្រមូលផលត្រី ។

អ្នកផ្សព្វផ្សាយគួរឱ្យដំបូន្មានកសិករ នូវអនុសាសន៍មួយចំនួនដូចខាងក្រោមនេះ ៖

- ការប្រមូលផលគួរធ្វើនៅពេលព្រឹក ព្រោះអាកាសធាតុនៅត្រជាក់ មិនក្តៅខ្លាំង ហើយខ្យល់អុកស៊ីសែ្សន ក្នុងទឹកស្រះនៅមានសម្បូរ។ គួរកុំប្រមូលផលត្រីនៅពេលយប់ ព្រោះកំរិតខ្យល់អុកស៊ីសែ្សនក្នុងទឹកស្រះ នៅពេលនោះមានតិច ដែលអាចធ្វើឱ្យត្រីឆាប់ងាប់ ក្រោយពេលប្រមូលផលត្រីហើយ ។
- ជាធម្មតាកសិករត្រូវប្រើម៉ាស៊ីនបូមទឹក ដើម្បីធ្វើការប្រមូលផលត្រីទាំងស្រុង
- មុនពេលចាប់ផ្តើមប្រមូលផលត្រីទាំងស្រុង កសិករត្រូវរៀបចំសំភារៈទុកដាក់ត្រីឱ្យហើយ ដើម្បីរក្សាត្រី នៅរស់បានយូរ ក្រោយពីប្រមូលផលហើយ ។





## ២.១៣- ការវិភាគសេដ្ឋកិច្ច

តារាងខាងក្រោមនេះ ជាឧទាហរណ៍នៃការវិភាគសេដ្ឋកិច្ច ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ក្នុងស្រះទំហំ ១០០ ម២ ក្នុងករណីចិញ្ចឹមបានរយៈពេល ៨ ខែ ទទួលបានលទ្ធផលដូចខាងក្រោម:

| សកម្មភាព | ប្រព័ន្ធចិញ្ចឹមតាមទំលាប់ | | | | ប្រព័ន្ធចិញ្ចឹមត្រូវបានកែលំអ | | | |
|---|---|---|---|---|---|---|---|---|
| | ឯកតា | ចំនួន | តម្លៃរាយ (៛) | តម្លៃសរុប (៛) | ឯកតា | ចំនួន | តម្លៃរាយ (៛) | តម្លៃសរុប (៛) |
| **ការជីកស្រះ** | | | | | | | | |
| ស្រះថ្មី | $m^3$ | 87 | 3,000 | **261,000** | $m^3$ | 87 | 3,000 | **261,000** |
| **ការរៀបចំស្រះ** | | | | | | | | |
| ថ្លៃឈ្នួលបូមទឹកស្រះ | ម៉ោង | 0 | 0 | 0 | ម៉ោង | 3 | 5,000 | 15,000 |
| កំបោរ | គ.ក្រ | 0 | 0 | 0 | គ.ក្រ | 10 | 1,200 | 12,000 |

DRAFT

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ដីអ៊ុយរ៉េ | គ.ក្រ | 0 | 0 | 0 | គ.ក្រ | 1.5 | 1,600 | 2,400 |
| ដីដេអាប៉េ | គ.ក្រ | 0 | 0 | 0 | គ.ក្រ | 0.5 | 1,800 | 900 |
| ដីលាមកសត្វ | គ.ក្រ | 40 | 0 | 0 | គ.ក្រ | 40 | 0 | 0 |
| ដីរុក្ខជាតិបៃតង | គ.ក្រ | 10 | 0 | 0 | គ.ក្រ | 10 | 0 | 0 |
| សរុប | | | | **0** | | | | **30,300** |
| **ការដាក់កូនត្រីចិញ្ចឹម** | | | | | | | | |
| ៣- ៤ ប្រភេទ | ក្បាល | 600 | 40 | **24,000** | ក្បាល | 300 | 80 | **24,000** |
| **ការផ្តល់ចំណីបន្ថែម** | | | | | | | | |
| កន្ទក់ | គ.ក្រ | 20 | 550 | 11,000 | គ.ក្រ | 20 | 550 | 11,000 |
| ចក | គ.ក្រ | 50 | | 0 | គ.ក្រ | 50 | | 0 |
| កណ្តៀរ ឬ ជន្លេន | គ.ក្រ | 5 | | 0 | គ.ក្រ | 5 | | 0 |
| កាកសំណល់បន្លែ | គ.ក្រ | 10 | | 0 | គ.ក្រ | 10 | | 0 |
| សរុប | | | | **11,000** | | | | **11,000** |
| **ការគ្រប់គ្រងស្រះ** | | | | | | | | |
| ដីអ៊ុយរ៉េ | គ.ក្រ | 0 | 0 | 0 | គ.ក្រ | 1.5 | 1,600 | 2,400 |
| ដីដេអាប៉េ | គ.ក្រ | 0 | 0 | 0 | គ.ក្រ | 0.5 | 1,800 | 900 |
| ដីលាមកសត្វ | គ.ក្រ | 40 | 0 | 0 | គ.ក្រ | 40 | 0 | 0 |
| ដីរុក្ខជាតិបៃតង | គ.ក្រ | 10 | 0 | 0 | គ.ក្រ | 10 | 0 | 0 |
| សរុប | | | | **0** | | | | **3,300** |
| ប្រាក់ចំណាយសរុប | | | | **35,000** | | | | **68,600** |
| ប្រាក់ចំណូលសរុបពីផលត្រី | គ.ក្រ | 10 | 5,000 | 50,000 | គ.ក្រ | 36 | 5,000 | 180,000 |
| ប្រាក់ចំណេញសរុប= ប្រាក់ចំណូលសរុប- ប្រាក់ចំណាយសរុប | | | | **15,000** | | | | **111,400** |
| ប្រាក់ចំណាយបន្ទាប់បន្សំលើការផលិតកូនត្រីទីឡាព្យ៉ា (ហាប៉ា ថ្មង) | | | | 0 | ចំនួន | 1 | 50,000 | 50,000 |
| ប្រាក់ចំណូលបន្ទាប់បន្សំលើការផលិតកូនត្រីទីឡាព្យ៉ា | | | | 0 | ក្បាល | 2,000 | 50 | 100,000 |
| ប្រាក់ចំណេញបន្ទាប់បន្សំលើការផលិតកូនត្រីទីឡាព្យ៉ា | | | | 0 | | | | **50,000** |
| % នៃការបង្វិលទុនបន្ទាប់បន្សំ = (ប្រាក់ចំណូល- ប្រាក់ចំណាយ)/ ប្រាក់ចំណាយបន្ទាប់បន្សំ | | | | | | | | 100% |
| ប្រាក់ចំណេញសរុបរួម= (ប្រាក់ចំណូលសរុប- ប្រាក់ចំណាយសរុប) + ប្រាក់ចំណេញបន្ទាប់បន្សំ | | | | | | | | **161,400** |

DRAFT

## ៣. វិធីសាស្ត្រផ្សព្វផ្សាយ

### ៣.១- វិធីសាស្ត្រអនុវត្ត

ការផ្សព្វផ្សាយជាយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ ក្នុងការជំរុញការងារអភិវឌ្ឍន៍ឱ្យមានការរីកចម្រើន ជាពិសេសការផ្សព្វផ្សាយធ្វើឡើងដោយក្រុមអ្នកផ្សព្វផ្សាយ ឬដោយពីកសិករមួយទៅកសិករមួយទៀត។ ការជួបប្រជុំ ឬ សិក្ខាសាលាជាមួយកសិករជារូបភាពមួយនៃការងារផ្សព្វផ្សាយ ដើម្បីធ្វើការប៉ាន់ប្រមាណពីតម្រូវការ ស្វែងរកបញ្ហា និងដំណោះ

ស្រាយបញ្ហា ព្រមទាំងស្វែងរកកសិករមានបទពិសោធន៍ល្អៗ ដែលនឹងត្រូវជំរុញអភិវឌ្ឍន៍សមត្ថភាពបច្ចេកទេសបន្ថែមទៀត ។ អ្នកជំនាញបច្ចេកទេសចិញ្ចឹមត្រី ត្រូវបង្កើនការងារបណ្តុះបណ្តាលបច្ចេកទេសដល់កសិករទាំងនោះ រួចធ្វើការតាមដានវាយតម្លៃសមត្ថភាព តាមរយៈចុះត្រួតពិនិត្យផ្ទាល់ និងជួបប្រជុំសិក្ខាសាលា ។

ដ្យាក្រាមសង្ខេបខាងក្រោម ជាជំហ៊ាននៃការផ្សព្វផ្សាយរបស់ឯកសារបច្ចេកទេសនេះ ។ ដំណាក់កាលនិមួយៗមានរៀបរាប់លំអិតដូចខាងក្រោមនេះ




### ការជ្រើសរើសទីកន្លែង

ការជ្រើសរើសទីកន្លែង ដើម្បីអភិវឌ្ឍន៍សកម្មភាពចិញ្ចឹមត្រី ជាកត្តាសំខាន់ក្នុងការកំណត់នូវភាពជោគជ័យរបស់គម្រោង ហើយជាទូទៅអាចអនុវត្តចាប់ពីខែ មករា ដល់ខែ មេសា ។ ខាងក្រោមនេះ ជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីកន្លែង អភិវឌ្ឍន៍សកម្មភាពចិញ្ចឹមត្រី (រួមទាំងចំណុចលំអិត ២.២)

- ត្រូវមានការសហការល្អ និងទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋាន
- បរិមាណផលត្រីក្នុងធម្មជាតិមិនអាចបំពេញតាមតម្រូវការរបស់ប្រជាពលរដ្ឋ
- កសិករជាច្រើនជាអ្នកក្រខ្សត់
- កសិករពេញចិត្តនឹងសកម្មភាពចិញ្ចឹមត្រី និងចាត់ទុកជាមុខរបរសម្រាប់ចិញ្ចឹមជីវិត
- មានកសិករកំពុងចិញ្ចឹមត្រី តែពុំបានទទួលការបណ្តុះបណ្តាលពីគម្រោងផ្សេងៗ និងពីអ្នកផ្សព្វផ្សាយ
- ខ្វះកូនត្រីពូជផ្គត់ផ្គង់ឱ្យអ្នកកំពុងបន្តចង់ចិញ្ចឹមត្រី និងកសិករដែលចង់ចិញ្ចឹមត្រីដោយមានការឧបត្ថម្ភ ពីគម្រោងនានា ឬដោយស្ម័គ្រចិត្ត

- មានប្រភពទឹកគ្រប់គ្រាន់សម្រាប់ចិញ្ចឹមត្រីរយៈពេលយ៉ាងហោចណាស់ ៦ ខែ
- មិនលិចទឹកនៅរដូវវស្សា
- សម្បូរស្រះចិញ្ចឹមត្រីសម្រាប់ពង្រីកការអភិវឌ្ឍន៍
- សម្បូរធនធានធម្មជាតិសម្រាប់បម្រើដល់ការអភិវឌ្ឍន៍សកម្មភាពចិញ្ចឹមត្រី
- ជាទីតាំងអាចជ្រើសរើសកសិករផលិតកូនត្រីពូជបានទៅថ្ងៃក្រោយ

**ការរៀបចំសិក្ខាសាលាកសិករ**

ក្រោយពីការជ្រើសរើសទីកន្លែង ត្រូវរៀបចំសិក្ខាសាលាកសិករមួយ ដើម្បីធានាអោយបានថា ការធ្វើបង្ហាញអាចចាប់ផ្តើមនៅក្នុងខែ ឧសភា ឬ ឆាប់អនុវត្តនៅពេលដែលទឹកនៅក្នុងស្រះត្រូវបំពេញដោយទឹកភ្លៀងនៅ រដូវវស្សា ។

សិក្ខាសាលាប្រមូលព័តិមានពីកសិករ គឺដើម្បីធានាអោយបានច្បាស់ថា ការជ្រើសរើសកសិករ មាន លក្ខណៈវិនិច្ឆ័យសមស្របតាមគោលដៅឬទេ ។ សិក្ខាសាលានេះក៏ផ្តល់នូវវិធីសាស្រ្ត នៃដំណើរការនៃការធ្វើបង្ហាញដែរ ។

**ការរៀបចំផែនការសកម្មភាព**

ផែនការសកម្មភាព អាចត្រូវរៀបចំធ្វើឡើងដោយផ្អែកលើ ព័តិមានដែលប្រមូលបានពីការធ្វើសិក្ខាសាលាកសិករ ។ ផែនការនេះបង្ហាញខ្លឹមសារសង្ខេបនូវពេលវេលានៃដំណើរការធ្វើបង្ហាញ ។

ឧទាហរណ៍ខាងក្រោមជាផែនការសកម្មភាពមួយ ប៉ុន្តែទោះជាយ៉ាងណាក៏វានៅតែមានការផ្លាស់ប្តូរជាយថាហេតុ ដោយអាស្រ័យលើរបបទឹកភ្លៀង

| សកម្មភាព | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការជ្រើសរើសទីកន្លែង | | | | | | | | | | | | |
| ការរៀបចំសិក្ខាសាលាកសិករ | | | | | | | | | | | | |
| ការរៀបចំផែនការ | | | | | | | | | | | | |
| ការជ្រើសរើសកសិករ | | | | | | | | | | | | |
| រៀបចំធ្វើបង្ហាញ សកម្មភាពចិញ្ចឹមត្រី | | | | | | | | | | | | |
| ផ្តល់វគ្គបណ្តុះបណ្តាល | | | | | | | | | | | | |
| ផ្តល់សំភារៈខ្លះៗ សម្រាប់អនុវត្ត | | | | | | | | | | | | |
| តាមដានសកម្មភាព និងផ្សព្វផ្សាយ | | | | | | | | | | | | |
| វាយតម្លៃ និងធ្វើរបាយការណ៍ | | | | | | | | | | | | |
| រៀបចំសិក្ខាសាលាកសិករបញ្ចប់ | | | | | | | | | | | | |
| រៀបចំផែនការអនុវត្តបន្ត | | | | | | | | | | | | |
| ជ្រើសរើសកសិករផលិតកូនត្រីពូជ | | | | | | | | | | | | |

DRAFT

**ការជ្រើសរើសកសិករ**

ដើម្បីជ្រើសរើសកសិករចិញ្ចឹមត្រីនៅតាមទីកន្លែងដែលធ្វើបង្ហាញ គួរជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យ ដូចក្នុងចំណុច២.២ ហើយព័ត៌មានក្នុងការជ្រើសរើសកសិករនេះ មាននៅក្នុងចំណុចសិក្ខាសាលាកសិករ ។

**រៀបចំធ្វើបង្ហាញសកម្មភាពចិញ្ចឹមត្រី**

ផ្នែកនេះចាប់ផ្តើមអនុវត្តផែនការសកម្មភាពសម្រាប់ការធ្វើបង្ហាញដោយប្រើស្រះចិញ្ចឹមត្រីរបស់កសិករ

ដើម្បីធ្វើអោយមានប្រសិទ្ធភាពអតិបរមាក្នុងការប្រើប្រាស់ធនធាន, អ្នកផ្សព្វផ្សាយគួរធ្វើការជ្រើសរើសតាម ការចាប់ឆ្នោតដោយចៃដន្យ ដោយជ្រើសរើសកសិករពី ៥ ទៅ ១០ នាក់ក្នុងមួយភូមិ ពីក្រុមកសិករ ដែលបានជ្រើសរើស

**ការផ្តល់វគ្គបណ្តុះបណ្តាល**

ត្រូវរៀបចំផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឱ្យកសិករ ដែលបានជ្រើសរើសដោយមានរៀបចំការងារអនុវត្តបច្ចេកទេស ចិញ្ចឹមត្រីសំខាន់ៗក្នុង TIP នេះ ។ វគ្គបណ្តុះបណ្តាលនេះគួររៀបចំនៅកសិដ្ឋានចិញ្ចឹមត្រី ។

ក្រៅពីនេះមានសំភារៈសម្រាប់បណ្តុះបណ្តាលមួយចំនួនទៀតដូចជា ផ្ទាំងរូបភាព និង ខិត្តប័ណខ្លីៗ គួរចែកអោយកសិករជាសិក្ខាកាមនៅក្នុងពេលបណ្តុះបណ្តាល ។

គួរអញ្ជើញរដ្ឋអំណាចក្នុងមូលដ្ឋានចូលរួមបើកវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសនៃព័ត៌មានការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារអោយមានប្រសិទ្ធភាព ទូលំទូលាយ ។

**ការផ្តល់សំភារៈខ្លះៗសម្រាប់អនុវត្ត**

សំភារៈខ្លះៗដែលមិនអាចផលិតបានដោយកសិករ អាចត្រូវផ្តល់អោយដើម្បីសហការនិងចែករំលែកបទ ពិសោធន៍ជាមួយកសិករដែលបានជ្រើសរើស និងផ្សព្វផ្សាយព័ត៌មាន បទពិសោធន៍ទៅអោយកសិករដទៃទៀត នៅក្នុង ភូមិ និងភូមិជិតៗនោះ ។ ខាងក្រោមនេះគឺជាសេចក្តីណែនាំសម្រាប់ការចូលរួមចំណែកទាំងសងខាង ពីម្ចាស់ទុន និង កសិករ ។ យោងទៅតាមទិសដៅនៃកម្មវិធីផ្សព្វផ្សាយ ទុនសំភារៈអាចត្រូវបានប្តូររវាងប្រភព២ផ្សេងគ្នា ។

*ប្រភេទសំភារៈដែលគួរផ្តល់ឱ្យដោយគម្រោង:*

- កូនត្រីពូជ
- ជីគីមី ដូចជា ជីអ៊ុយរ៉េ និងជីដេអាប៉េ

គួរចំណាំថា ទុនចូលរួមសម្រាប់កសិករគួរធ្វើតែឆ្នាំដំបូងប៉ុណ្ណោះ ។ ចាប់ពីឆ្នាំបន្ទាប់នោះកសិករគួរតែទទួលខុសត្រូវដោយខ្លួនគាត់ ។

*ទុនចូលរួមចំណែកពីកសិករមាន:*

- ស្រះចិញ្ចឹមត្រី
- ប្រេងសម្រាប់បូមទឹកស្រះ
- ជីធម្មជាតិ ឬ ជីសរីរាង្គ
- ចំណីសម្រាប់ចិញ្ចឹមត្រី (កន្ទក់ ម្សៅត្រី ចកបាយទា ជន្លេន កណ្តៀរ .....)

DRAFT

- កម្លាំងពលកម្មមើលគ្រប់គ្រងស្រះចិញ្ចឹមត្រី

**ការចុះពិនិត្យសកម្មភាពចិញ្ចឹមត្រីរបស់កសិករ និងផ្សព្វផ្សាយបច្ចេកទេស**

ការចិញ្ចឹមត្រីជាសកម្មភាពមួយថ្មី សម្រាប់កសិករនៅតាមជនបទ ជាពិសេសកសិករដែលពុំមានបទពិសោធន៍ចិញ្ចឹមត្រី ។ ដូចនេះទោះបីជា កសិករត្រូវបានទទួលការបណ្តុះបណ្តាលក៏ដោយ ក៏អ្នកផ្សព្វផ្សាយត្រូវឧស្សាហ៍ចុះត្រួតពិនិត្យសកម្មភាពចិញ្ចឹមត្រីរបស់កសិករ ដើម្បីផ្តល់ដំបូន្មានបច្ចេកទេសបន្ថែមដល់គាត់ ធ្វើយ៉ាងណាឱ្យគាត់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការចិញ្ចឹមត្រីឱ្យបានជោគជ័យ ។

- ចុះពិនិត្យ ដើម្បីវាយតម្លៃសមត្ថភាពកសិករ ក្នុងការអនុវត្តសៀវភៅផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ដោយស្វែងរកបញ្ហាបច្ចេកទេសឱ្យឃើញ និងផ្តល់វិធានការណ៍ដល់កសិករ ដើម្បីដោះស្រាយ។ អ្នកផ្សព្វ ផ្សាយគួរចុះជួយផ្តល់ដំបូន្មានដល់កសិករ ឱ្យបានយ៉ាងហោចណាស់មួយដង ក្នុងមួយសប្តាហ៍ ។
- ក្នុងពេលចុះពិនិត្យ អ្នកផ្សព្វផ្សាយគួរកត់ត្រាគ្រប់ព័ត៌មាន ទាំងបញ្ហាកសិករបានជួបប្រទះ និងសកម្មភាព រីកចម្រើន ដើម្បីងាយស្រួលវាយតម្លៃសមត្ថភាព និងផ្តល់ដំបូន្មានកសិករនៅពេលក្រោយ
- ត្រួតពិនិត្យគុណភាពទឹក និងសកម្មភាពត្រីក្នុងស្រះ ដោយដាក់ចំណីឱ្យស៊ី
- អ្នកផ្សព្វផ្សាយត្រូវរៀបចំរបាយការណ៍សង្ខេបពីលទ្ធផលសកម្មភាពចិញ្ចឹមត្រីរបស់កសិករ រួចធ្វើបទបង្ហាញនៅពេលសិក្ខាសាលា ដើម្បីឱ្យកសិករបានដឹង និងរៀនសូត្រពីគ្នាទៅវិញទៅមក នៅពេលចុងបញ្ចប់សកម្មភាពចិញ្ចឹមត្រីដែលជាធម្មតាច្រើនធ្វើនៅក្នុងខែ មីនា ឬ ខែមេសា ។
- ក្នុងករណីចាំបាច់ ដែលអ្នកផ្សព្វផ្សាយចង់ផ្តល់ព័ត៌មាន ឬដោះស្រាយបច្ចេកទេសអ្វីមួយដល់កសិករ សិក្ខាសាលានេះអាចរៀបចំ នៅពេលណាមួយក៏បានក្នុងអំឡុងពេលកំពុងចិញ្ចឹមត្រី ។

**ការវាយតម្លៃ និងធ្វើរបាយការណ៍**

តាមរយៈការចុះពិនិត្យសកម្មភាពចិញ្ចឹមត្រីរបស់កសិករនេះ អ្នកផ្សព្វផ្សាយអាចធ្វើការវាយតម្លៃ ពីលទ្ធផលនៃទស្សនៈកិច្ច និងផ្តល់ ព័ត៌មានពីការរីកចម្រើន ពីបញ្ហាបច្ចេកទេសនិងបញ្ហាផ្សេងៗទៀត ដែលកសិករបានជួបប្រទះ និងផ្តល់ជាដំណោះស្រាយ ។

សិក្ខាសាលាកសិករ

ការរៀបចំសិក្ខាសាលាកសិករធ្វើឡើងបន្ទាប់ពីការប្រមូលផលត្រីរួច ដើម្បីផ្តល់ឱកាសដល់កសិកររៀនសូត្រពី គ្នាទៅវិញទៅមក ដោយធ្វើការផ្លាស់ប្តូរនូវបទពិសោធន៍ និងបង្កើនចំណេះដឹង ដើម្បីធ្វើអោយប្រសើរឡើងនូវជោគជ័យសម្រាប់ការចិញ្ចឹមត្រីនៅឆ្នាំក្រោយទៀត ។

ការជ្រើសរើសកសិករផលិតកូនត្រីពូជ

នៅពេលសកម្មភាពចិញ្ចឹមត្រីត្រូវបានអភិវឌ្ឍន៍ កសិករនឹងជួបបញ្ហាការខ្វះកូនត្រីពូជសម្រាប់ដាក់ចិញ្ចឹម ។ ដើម្បីដោះស្រាយបញ្ហានេះ អ្នកផ្សព្វផ្សាយត្រូវជ្រើសរើសកសិករចិញ្ចឹមត្រីណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួចធ្វើការបណ្តុះបណ្តាលសមត្ថភាពបច្ចេកទេសផលិតកូនត្រីពូជតាមទីកន្លែងរបស់គាត់ ។ ខាងក្រោមនេះ ជាលក្ខណៈ វិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រីពូជៈ

**បុគ្គលិកលក្ខណ**

- ពេញចិត្តនឹងមុខរបរផលិតកូនត្រីពូជ
- មានចរិកតស៊ូ ឧស្សាហ៍ព្យាយាម និងមានបទពិសោធន៍ច្រើនពីការចិញ្ចឹមត្រី និងទីផ្សារ
- ជាកសិករដែលចូលរួមធ្វើការជាមួយមន្ត្រីផ្សព្វផ្សាយក្នុងតំរោង

**ធនធានតម្រូវការ**

- មានផ្ទៃដីទូលាយអាចពង្រីកស្រះចិញ្ចឹមត្រី និងផលិតកូនត្រីពូជបាន
- មានកម្លាំងពលកម្មគ្រប់គ្រាន់
- មានទុនផ្ទាល់ខ្លួនសម្រាប់ចំណាយលើសកម្មភាពផលិតកូនត្រី
- ក្នុងភូមិមានធនធានធម្មជាតិ សម្រាប់ប្រើប្រាស់ជាចំណីត្រី ដូចជា ចក ជន្លេន កណ្ដៀរ.... រុក្ខជាតិបៃតង
- មានលាមកគោ ក្របី ជ្រូក ឬ លាមក មាន់ ទា សម្រាប់ប្រើជាជី ដាក់ស្រះត្រី
- មានប្រភពទឹកគ្រប់គ្រាន់ពេញមួយឆ្នាំ ដូចជា (ស្រះស្តុកទឹកធំ អណ្តូងទឹក ប្រឡាយ ជាដើម....)
- មានអាងបង្កាត់ ភ្ញាស់កូនត្រីពូជ និងមានម៉ាស៊ីនបូមទឹក

មានត្រីមេពូជច្រើនផ្សេងៗគ្នា សម្រាប់បង្កាត់ ភ្ញាស់

**៣.២- ថវិកាសម្រាប់ការធ្វើបង្ហាញ**

វិធីសាស្ត្រផ្សព្វផ្សាយបានបង្ហាញឡើងពីកម្មវិធីមួយ លើទំនាក់ទំនងកំរិតខ្ពស់ រវាងគ្រូបណ្តុះបណ្តាល និង កសិករ លើចំនួនដែលធ្វើបង្ហាញពិតប្រាកដ ពីបច្ចេកទេសថ្មី ។

តម្លៃដែលបានរៀបរៀងឡើងខាងក្រោមនេះ សម្រាប់តែការធ្វើបង្ហាញជាក់ស្តែងប៉ុណ្ណោះ ដើម្បីតម្រូវទៅនឹងការងារផ្សព្វផ្សាយ បអប ។

| | **សកម្មភាព** | **ចំនួន -តម្លៃ** |
|---|---|---|
| ក | ក្រុមកសិករ | ៣០ នាក់ |
| ខ | ទុនចូលរួមពីកសិករគំរូ | កម្លាំងពលកម្ម ស្រះចិញ្ចឹមត្រី ចំណីត្រី ជីធម្មជាតិ |
| គ | ទុនសម្រាប់ទីតាំងធ្វើបង្ហាញ | $ ៩៤ |
| ឃ | ឯកសារសម្រាប់ការបណ្តុះបណ្តាលក្រុមកសិករ | $ ៣០ |
| ង | ការបណ្តុះបណ្តាលក្រុមកសិករ- អាហារសំរ៉ន់ | $ ៩០ |
| ច | ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី- អាហារសំរ៉ន់ | $ ២៥ |
| ឆ | ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី- សំភារៈ | $ ១០ |
| ជ | មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ | $ ៤២ |
| ឈ | មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភថ្លៃធ្វើដំណើរ | $ ២៤ |
| ញ | ការចុះត្រួតពិនិត្យ តាមដាននៅមូលដ្ឋានដោយអ្នកឯកទេសជំនាញ | $ ២០ |
| | **សរុប** | **$ ៣៣៥** |

**សេចក្តីបញ្ជាក់ដោយសង្ខេប**

ក- ក្នុង បអប មួយមានក្រុមកសិករ ៣០ នាក់ និងកសិករគំរូ ដែលមានទីកន្លែងធ្វើបង្ហាញចំនួន ២កន្លែង ក្នុងមួយក្រុម (លើកលែងតែការចិញ្ចឹមជ្រូកប្រពលវប្បកម្ម មានបង្ហាញតែ ១កន្លែង និងមានកសិករចូលរួមចំនួន ១៥នាក់)

ខ- ទុនចូលរួមពីកសិករ (សម្រាប់ ១ កន្លែង) មានស្រះទំហំ ២០០ម២ ឧបករណ៍សម្រាប់ការចិញ្ចឹមត្រី ទឹកស្រះ កម្លាំងពលកម្ម ចំណីត្រី (កន្ទក់ ចុងអង្ករ ចកបាយទា កណ្តៀរ ជន្លេន ....) និងជីធម្មជាតិ (លាមកគោ ក្របី ជ្រូក មាន់ ទា)

គ- ទុនសម្រាប់ធ្វើបង្ហាញការចិញ្ចឹមត្រីក្នុងស្រះ១ កន្លែង ដោយមានរួមបញ្ចូល -ការរៀបចំស្រះទំហំ ២០០ម២= **$២០**

- កូនត្រីដាក់ចិញ្ចឹម ៣ក្បាល/ម២ x ២០០ម២ x ១០០៛/ ក្បាល = **$១៥** - ចំណីត្រី =4៥ -ជីគីមី = **$២**

-ការដឹកជញ្ជូន = **$៥** -សរុបទាំងអស់ = **$៤៧** ។ ដូចនេះ ការធ្វើបង្ហាញ ២ កន្លែង អស់ប្រាក់ **$៩៤** ។

ឃ- ឯកសារបណ្តុះបណ្តាលបច្ចេកទេស រួមមាន សំភារៈសម្រាប់បង្រៀន - មេរៀន - ការបញ្ចាំងស្លាយ -និងផ្ទាំងរូប ភាពធំៗ ដែលជាដំណើរការវិធីសាស្ត្របង្រៀន ។

ង- ការបណ្តុះបណ្តាលក្រុមកសិករមាន ៣ វគ្គ មួយវគ្គមានរយៈពេល ១ ថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្តិ៍ មានតែ ២វគ្គទេ និង ការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គ

ច- ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី មានកន្លះថ្ងៃ មានតែម្តងក្នុងវគ្គណាមួយ ក្នុងចំណោម ៣ វគ្គ និងអាចមានការចូលរួម ពីកសិករនៅក្បែរៗភូមិប្រហែល ៤០- ៦០ នាក់ ។

ឆ- សំភារៈសម្រាប់ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី រួមមាន ឧឃោសនស័ព្ទ (មេក្រូ) ផ្ទាំងក្រដាស់ផ្លាស្ទិក និងផ្ទាំងបដា រូបភាពផ្សេងៗ

ជ- សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន ៤ ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងធ្វើបង្ហាញ ការចាប់ផ្តើមការត្រួតពិនិត្យតាមដាន ។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ៣ វគ្គ ផ្តល់ឱ្យ ៦ថ្ងៃ និង ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រីផ្តល់ឱ្យ ២ថ្ងៃ -សរុប ១២ ថ្ងៃ ។

ឈ- ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ ដុល្លា សម្រាប់ ១ ថ្ងៃ ទាំងអស់ ១២ ថ្ងៃ

ញ- មន្ទីរកសិកម្មខេត្ត- អ្នកឯកទេសជំនាញផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ ចុះតាមដានការបណ្តុះបណ្តាល បអប សម្រាប់ការធ្វើបង្ហាញ

## ៣.៣- ធនធានសំភារៈ

ការិយាល័យវារីវប្បកម្ម នៃរដ្ឋបាលជលផល ដែលកំពុងសហប្រតិបត្តិការជាមួយបណ្តាអង្គការនានា និងជា មួយបណ្តាស្ថានីយស្រាវជ្រាវ ផលិតកូនត្រីពូជ ជាមជ្ឈមណ្ឌលផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី និងផលិតឯកសារ ផ្សព្វផ្សាយ ។

## ៣.៤- ការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាពវារីវប្បកម្ម

ស្ត្រីជាធនធានមនុស្សមួយយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សកម្មភាពចិញ្ចឹមត្រី និងអនុវត្តបច្ចេកទេសចិញ្ចឹមត្រីក្នុងសៀវភៅបច្ចេកទេសនេះដល់គ្រួសារកសិករដទៃទៀត ។ ស្ត្រីអាចចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយបច្ចេក

ទេសចិញ្ចឹមត្រីក្នុងតំបន់ និង នៅក្រៅតំបន់ ពិសេសចូលរួមយ៉ាងសកម្មក្នុងសកម្មភាពផ្សារភ្ជាប់រវាងគ្រួសារមួយ ទៅគ្រួសារមួយនៅកសិដ្ឋានចិញ្ចឹមត្រី ។ សៀវភៅផ្សព្វផ្សាយបច្ចេកទេសនេះ នឹង ផ្តល់ដល់ស្ត្រីនូវការរកប្រាក់ចំណូល ក្នុងគ្រួសារតាមរយៈការចិញ្ចឹមត្រី ដើម្បីលើកស្ទួយជីវភាពរស់នៅ ក្នុងការបង្កើនសារធាតុប្រូតេអ៊ីនក្នុងម្ហូបអាហារ និង ផ្គត់ផ្គង់កូនចៅទៅសាលារៀន ព្រមទាំងសម្រាប់ការចំណាយផ្សេងៗទៀត ។

## ៤~ សេចក្តីបន្ថែម

### ៤.១- កត្តាសំខាន់ៗ ដែលធ្វើឱ្យត្រីពុល និងស្លាប់ និងវិធានការដោះស្រាយ

ក្នុងអំឡុងពេលចិញ្ចឹមត្រី ជួនកាលកសិករបានជួបប្រទះនឹងបញ្ហាបច្ចេកទេសមួយចំនួន ដែលធ្វើឱ្យត្រីឈឺ និងងាប់ ។ ដូចនេះ តើយើងត្រូវដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច ? ខាងក្រោមនេះ ជាបញ្ហាដែលធ្វើឱ្យត្រីឈឺ និងងាប់ និង ដំណោះស្រាយមួយចំនួន ដោយផ្អែកលើបទពិសោធន៍ការងារជាមួយកសិករនៅតាមមូលដ្ឋាន។

| កត្តាដែលធ្វើឱ្យត្រីពុល និងងាប់ | វិធានការណ៍ដោះស្រាយ |
|---|---|
| ដាក់ត្រីចិញ្ចឹមច្រើនពេក នៅក្នុងស្រះ(ដង់ស៊ីតេខ្ពស់ពេក) | ❑ ត្រូវដាក់កូនត្រីចិញ្ចឹម តែ៣ ទៅ ៤ក្បាល ក្នុង១ម² <br> ❑ ចាប់ត្រីលក់ខ្លះ ឬ យកទៅដាក់ស្រះផ្សេងទៀត <br> ❑ បើអាចធ្វើបាន ផ្លាស់ប្តូរទឹកចាស់ខ្លះចេញពីស្រះ ដោយដាក់ទឹកថ្មី ស្អាតជំនួសវិញ |
| ដាក់ចិញ្ចឹមប្រភេទត្រីស៊ីចំណីស្រទាប់បាត ច្រើនពេក ដូចជា ត្រីកាបសាមញ្ញ | ❑ ត្រូវដាក់កូនត្រីកាបសាមញ្ញចិញ្ចឹមតែ ៥ -១០ % ដើម្បីជៀសវាងការធ្វើឱ្យទឹកស្រះអ្នកល្អក់ <br> ❑ ក្នុងពេលរៀបចំស្រះ ត្រូវស្តារភក់បាតស្រះចេញ ដោយទុកតែ ១០-២០ស.ម |
| ដាក់ចំណីឱ្យត្រីស៊ីច្រើនពេក លើសពីបរិមាណត្រី ដែលមានក្នុងស្រះ | ❑ ត្រូវផ្តល់ចំណីឱ្យត្រីស៊ីទៅតាមបរិមាណត្រីដែលមានក្នុងស្រះ ដោយសាកល្បងដាក់បន្តិចម្តងៗជារៀងរាល់ថ្ងៃ ដើម្បីកុំឱ្យទឹកស្រះស្អុយ ។ កសិករអាចប្រើស៊ុមចំណី ពន្លិចទៅក្នុងទឹកស្រះ ។ <br> ❑ បើអាចធ្វើបាន ផ្លាស់ប្តូរទឹកចាស់ខ្លះចេញពីស្រះ ដោយដាក់ទឹកថ្មី ស្អាតជំនួសវិញ |
| បាចជីទៅក្នុងទឹកស្រះច្រើនពេក លើសពីផ្ទៃទឹក ស្រះដែលមាន ឬបាចជីច្រើនដងពេក | ❑ ត្រូវបាចជីទៅតាមទំហំទឹកស្រះដែលមាន និងមិនត្រូវបាចជី ពេលទឹកស្រះ នៅមានពណ៌បៃតងនៅឡើយ ដើម្បីកុំឱ្យទឹកស្រះស្អុយ ។ <br> ❑ អាចប្រើប្រាស់កំបោរក្នុងបរិមាណតិចតួច បាចលើផ្ទៃស្រះ តែជៀសវាងកុំប្រើនៅក្រោយពេលដាក់កូនត្រីចិញ្ចឹម ឬ នៅពេលកូនត្រីមានទំហំតូច <br> ❑ បើអាចធ្វើបាន ផ្លាស់ប្តូរទឹកចាស់ខ្លះចេញពីស្រះ ដោយដាក់ទឹកថ្មី ស្អាតជំនួសវិញ |
| មានសារធាតុសរីរាង្គសត្វ ឬ រុក្ខជាតិងាប់ និង ស្អុយរលួយ អណ្តែតលើផ្ទៃទឹកស្រះ | ❑ ត្រូវប្រញាប់ស្រង់ សារធាតុសរីរាង្គសត្វ ឬ រុក្ខជាតិងាប់ និង ស្អុយរលួយ អណ្តែតលើផ្ទៃទឹកស្រះនោះចេញ <br> ❑ អាចប្រើប្រាស់កំបោរក្នុងបរិមាណតិចតួច បាចលើផ្ទៃស្រះ តែជៀសវាងកុំប្រើនៅក្រោយពេលដាក់កូនត្រីចិញ្ចឹម ឬ នៅពេលកូនត្រីមានទំហំតូច ព្រោះវាអាច |

DRAFT

| | |
|---|---|
| | ធ្វើឱ្យត្រីងាប់មួយរំពេច ។ |
| មានរុក្ខជាតិទឹក ដូចជា ត្រកួន កំប្លោក ចក ព្រលិត ។ល។ ដុះគ្របដណ្តប់ផ្ទៃស្រះមានបរិមាណប្រហែលជា ៦០ ភាគរយនៃផ្ទៃស្រះ | ❑ ត្រូវសំអាតស្រះកុំឱ្យមាន ត្រកួន កំប្លោក ចក ព្រលិត ដុះគ្របដណ្តប់ពេញផ្ទៃស្រះឱ្យសោះ ព្រោះវាធ្វើឱ្យត្រីថប់ដង្ហើម។<br>❑ ជាពិសេស នៅពេលយប់ ព្រោះរុក្ខជាតិទាំងនេះដកដង្ហើមស្រូបយកខ្យល់ អ៊ុកស៊ីសែនក្នុងទឹកស្រះនៅពេលយប់ ។ |
| ដាក់ចកឱ្យត្រីស៊ីច្រើនពេក ដែលធ្វើឱ្យមាននៅសល់ ចកច្រើនគ្របដណ្តប់ពេញផ្ទៃស្រះ | ❑ ត្រូវប្រើស៊ុមឈើដាក់នៅកាច់ជ្រុងក្នុងទឹកស្រះ ហើយដាក់ចកឱ្យត្រីស៊ីក្នុងស៊ុមឈើនោះ ដើម្បីកុំឱ្យចកដែលនៅសល់ពីត្រីស៊ីអណ្តែតពេញផ្ទៃស្រះ ។ |
| មានត្រាំឈើ ឬស្លឹកឈើ ឬស្លឹកត្នោតក្នុងទឹកស្រះ | ❑ ក្នុងរយៈពេលចិញ្ចឹមត្រី កសិករមិនត្រូវត្រាំឈើ ឬ ស្លឹកឈើ ឬ ស្លឹកត្នោត ក្នុងទឹកស្រះបានទេ<br>❑ អាចប្រើប្រាស់កំបោរក្នុងបរិមាណតិចតួច បាចលើផ្ទៃស្រះ តែជៀសវាងកុំប្រើនៅក្រោយពេលដាក់កូនត្រីចិញ្ចឹម ឬ នៅពេលកូនត្រីមានទំហំតូច ព្រោះវាអាចធ្វើឱ្យត្រីងាប់មួយរំពេច ។ |
| មានស្លឹកឈើច្រើនជ្រុះចូលក្នុងទឹកស្រះ ហើយត្រាំ ក្នុងទឹកស្រះអស់រយៈពេលយូរថ្ងៃ ។ | ❑ ត្រូវស្រង់ស្លឹកឈើនោះចេញភ្លាម រួចត្រូវកាប់មែកឈើ ដែលគ្របដណ្តប់លើផ្ទៃស្រះនោះចេញ |
| មានដើមឈើច្រើន ដុះគ្របដណ្តប់ពេញផ្ទៃស្រះ | ❑ ត្រូវកាប់មែកឈើចេញខ្លះ ពិសេសមែកឈើណាគ្របដណ្តប់លើផ្ទៃស្រះ ដើម្បីកុំឱ្យស្លឹកជ្រុះចូលក្នុងស្រះ និងមានម្លប់ច្រើនគ្របដណ្តប់ពេញផ្ទៃស្រះ |
| មេឃស្ទុះស្អាប់ ឬ គ្មានខ្យល់ និង ពន្លឺថ្ងៃ ឬ ក្រោយពេលភ្លៀងធ្លាក់ខ្លាំង | ❑ ក្នុងករណីនេះ បើឃើញមានត្រីពុលដោយវាងើបមាត់ឡើងលើផ្ទៃទឹកស្រះ កសិករត្រូវបាចទឹកស្រះឱ្យសាចឡើងលើបានច្រើនដង ។ ធ្វើដូចនេះដើម្បី ឱ្យខ្យល់រលាយចូលក្នុងទឹកស្រះបានច្រើន ។ |

DRAFT

## ៤.២- បញ្ហាដែលតែងតែកើតមានក្នុងពេលចិញ្ចឹមត្រី និង វិធានការដោះស្រាយ

| បញ្ហាដែលតែងតែកើតមានឡើង | វិធានការដោះស្រាយ |
|---|---|
| ១- **ត្រីងាប់ក្រោយពេលដឹកជញ្ជូន** អាចបណ្តាលមកពី ៈ-<br>❑ កូនត្រីមានសុខភាពមិនល្អ<br>❑ កូនត្រីមិនបានបង្អត់អាហារ ១ថ្ងៃ មុនពេលដឹកជញ្ជូន ឬ<br>❑ ដាក់បរិមាណកូនត្រីច្រើនពេកក្នុងថង់ ឬក្នុងធុង ក្នុងពេលដឹកជញ្ជូន ឬ | ❑ ត្រូវជ្រើសរើសកូនត្រី ដែលមានសកម្មភាពហែលរហ័ស រហួន មានពណ៌ភ្លឺថ្លា និងធំធាត់ល្អគ្មានរបួសឬស្នាមដំបៅ<br>❑ មុនពេលដឹកជញ្ជូនកូនត្រី ត្រូវបញ្ឈប់ផ្តល់ចំណីឱ្យកូនត្រីស៊ី រយៈពេល ១ថ្ងៃ<br>❑ គួរដាក់កូនត្រីតូចៗទំហំពី ១- ២ស.ម ចំនួនតែ ៣០០ ទៅ ៥០០ក្បាល ក្នុង១ថង់ទំហំ ៦០ ស.ម x ៨០ ស.ម<br>❑ ចំពោះកូនត្រីមានទំហំ ៥ស.ម អាចដាក់បាន ៣០០ ក្បាល ក្នុងមួយថង់ អាស្រ័យទៅនឹងចម្ងាយផ្លូវដឹកជញ្ជូន |

| | |
|---|---|
| ❑ ទឹកដែលដាក់កូនត្រីដឹកជញ្ជូននោះមិនល្អ ឬ<br>❑ ដឹកជញ្ជូននៅពេលថ្ងៃក្តៅខ្លាំងពេក ហើយផ្លូវឆ្ងាយទៀតផង<br>❑ ខ្យល់ដែលបានបញ្ចូលក្នុងថង់កូនត្រីមិនបានគ្រប់គ្រាន់ | ❑ ត្រូវយកទឹកស្រះថ្លាត្រជាក់ល្មម ឬកុំឱ្យល្អក់ពេក pH ល្អ និងកុំឱ្យមានក្លិនស្អុយ ប្រើសម្រាប់ការដឹកជញ្ជូន<br>❑ គួរដឹកជញ្ជូនកូនត្រីនៅពេលថ្ងៃមេឃត្រជាក់ ទើបល្អ<br>❑ ក្នុងការដឹកជញ្ជូនកូនត្រី ត្រូវប្រើថង់ ២ ជាន់ និងបញ្ចូលខ្យល់អ៊ុកស៊ីសែ្សនឱ្យបានពេញណែនល្អកុំឱ្យធ្លាយខ្យល់ចេញ |
| **២-ត្រីខាប់ក្រោយពេលដាក់ចិញ្ចឹម** អាចបណ្តាលមកពី ៖<br>❑ លែងកូនត្រីចូលក្នុងស្រះឆាប់រហ័សពេក ឬ<br>❑ លែងកូនត្រីនៅពេលថ្ងៃកំពុងក្តៅខ្លាំង<br>❑ លែងកូនត្រីចូលទៅក្នុងស្រះទឹក ដែលមានគុណភាពមិនល្អ ដូចជា ៖ ទឹកល្អក់ពេក មានក្លិនស្អុយ និងមានជាតិគីមីពុល ផ្សេងៗ.......<br>❑ លែងកូនត្រីចូលទៅក្នុងទឹកស្រះ ដែលបានប្រើបរិមាណកំបោរ ឬ ជីច្រើនពេក ហើយដែលពុំទាន់សាបជាតិអស់ នៅឡើយ ។<br>❑ បាចកំបោរចូលក្នុងស្រះកូនត្រី នៅក្រោយពេលលែងកូនត្រីចូលស្រះរួច ។ | ❑ ត្រូវត្រាំថង់កូនត្រីក្នុងស្រះទឹក ឱ្យបានរយៈពេលពី ៣ ទៅ ៥ នាទីសិន រួចផ្សៀងមាត់ថង់ឱ្យកូនត្រីចេញសន្សឹមៗទើបល្អ ។<br>❑ ត្រូវលែងកូនត្រីនៅពេលថ្ងៃ ដែលមានអាកាសធាតុត្រជាក់ កុំឱ្យក្តៅខ្លាំង ទើបកូនត្រីមានសុខភាពល្អ ។<br>❑ មុននឹងសំរេចចិត្តលែងកូនត្រីចូលក្នុងស្រះ ត្រូវធ្វើទឹកឱ្យមានពណ៌បៃតងល្អ គ្មានក្លិនស្អុយ និងគ្មានជាតិពុលផ្សេងៗ ..... ។ល។<br>❑ ត្រូវប្រើកំបោរ និងជីបាចស្រះត្រី ឱ្យបានមុនពេលលែងកូនត្រី ១អាទិត្យទើបល្អ<br>❑ ក្រោយពេលលែងកូនត្រីចូលស្រះ មិនត្រូវប្រើកំបោរបាចចូលក្នុងស្រះកូនត្រីជាដាច់ខាត ព្រោះវាធ្វើឱ្យកូនត្រីស្លាប់ភ្លាម |
| **៣- កូនត្រីចេះតែបាត់បង់ក្នុងរយៈពេលចិញ្ចឹម** អាចបណ្តាលមកពី:<br>❑ ក្នុងទឹកស្រះមានពពួកត្រីកាចរស់នៅ ដូចជា: ត្រីផ្ទក់ ក្រាញ់ អណ្តែង និង សត្វកាចដទៃទៀតដូចជា ពស់ កង្កែប កណ្តុរ អន្ទង់ ចាប ក្រចាត និងពពួកសត្វល្អិតទឹកដទៃទៀត ដែលបំផ្លាញកូនត្រី ។ | ❑ បើមានលទ្ធភាព ត្រូវប្រើផ្ទាំងសំណាញ់ហាប៉ា ឬផ្ទាំងស្បោងកៅស៊ូចោះប្រហោង ឬរាំងព្រួលព័ទ្ធជុំវិញស្រះ ឬ ក៏លើក ភ្លឺស្រែឱ្យខ្ពស់កំពស់កន្លះម៉ែត្រ ទើបត្រីកាចមិនអាចលោត ចូលស្រះបាន។<br>❑ ហើយត្រូវព្យាយាមចាប់កំចាត់ សត្វពស់ កង្កែប អន្ទង់ កណ្តុរ ក្រចាត ឱ្យបានតាមវិធីសាស្ត្រផ្សេងៗ ដែលអាច ធ្វើបាន ។<br>❑ មិនតែប៉ុណ្ណោះ អ្នកត្រូវកំចាត់ពពួកសត្វល្អិតទឹក តាមវិធី សាស្ត្រប្រើស៊ុមកំចាត់សត្វល្អិត និងអូសអួនចាប់វា នៅមុន ពេលដាក់កូនត្រីចិញ្ចឹម ។ |
| **៤- កូនត្រីមិនធំលូតលាស់** អាចបណ្តាលមកពី:<br>❑ ក្នុងទឹកស្រះពុំសូវមានចំណីធម្មជាតិច្រើន ឬ គ្មាន ឬ ទឹកស្រះពុំមានពណ៌បៃតងល្អ ឬ | ❑ ក្នុងរយៈពេលចិញ្ចឹមត្រី ត្រូវកែលំអគុណភាពទឹកស្រះ ឱ្យមានពណ៌បៃតងជាប់ជានិច្ច ដោយបាចជីឱ្យបានគ្រប់ ចំនួន |

DRAFT

| | |
|---|---|
| ❑ មានបរិមាណកូនត្រីច្រើនពេកក្នុងទឹកស្រះ ឬ<br><br>❑ កូនត្រី មានជម្ងឺអ្វីមួយ | និងទៀងទាត់ពេលវេលា ។<br>❑ មិនត្រូវដាក់កូនត្រីចិញ្ចឹមក្នុងស្រះច្រើនពេកទេ គួរដាក់តែ ២ ទៅ ៣ក្បាលក្នុង ១ម៉ែត្រការេ ស្រះប៉ុណ្ណោះ ទើបកូនត្រីលូតលាស់បានល្អ ។<br>❑ ក្នុងរយះពេលចិញ្ចឹមត្រី បើសង្កេតឃើញ ឬ សង្ស័យថាត្រីណាមួយមានជម្ងឺ ត្រូវចាប់វាចេញពីស្រះ ដើម្បីកុំឱ្យឆ្លងទៅត្រីផ្សេងទៀត ។ |
| **៥-កូនត្រី ឬត្រីធំខាប់ក្អួរយៈពេលចិញ្ចឹម**<br>អាចបណ្តាលមកពីៈ<br>❑ ទឹកស្រះមានជាតិពុល ដែលបណ្តាលមកពីមានសារធាតុគីមីពុលផ្សេងៗចូលក្នុងស្រះត្រី ឬ<br>❑ ទឹកស្រះមានរុក្ខជាតិទឹកដុះច្រើនពេក ឬ<br>❑ មាននៅសល់ចកគ្របដណ្តប់ពេញផ្ទៃស្រះ ឬ<br>❑ ទឹកស្រះរាក់ពេក ហើយថែមទាំងល្អក់ និងក្តៅទៀតផង<br>❑ ឬ មានភក់បាតស្រះច្រើនពេក ។ | ❑ ក្នុងរយះពេលចិញ្ចឹមត្រី មិនត្រូវលាងសំភារៈប្រើប្រាស់ថ្នាំ ពុល ឬ បញ្ចូលទឹកថ្មីដែលសង្ស័យថាមិនល្អ ចូលក្នុងស្រះ ត្រីឡើយ ។<br>❑ ក្នុងទឹកស្រះមិនត្រូវឱ្យមាន ត្រកួន ឬកំបោក និង រុក្ខជាតិទឹកដទៃទៀតដុះគ្របដណ្តប់លើសពី ៦05លើផ្ទៃស្រះទេ។<br>❑ ត្រូវដាក់ចកឱ្យត្រីស៊ី នៅក្នុងស៊ុមចំណី<br>❑ ក្នុងរយះពេលចិញ្ចឹម ត្រូវរក្សាទឹកឱ្យបានច្រើនជានិច្ចនៅក្នុងស្រះ ហើយត្រូវកែលំអគុណភាពទឹកស្រះឱ្យមានពណ៌បៃតងល្អជាប់ជានិច្ច។<br>❑ ពេលរៀបចំស្រះ ត្រូវបារភក់ចេញ ទុកឱ្យនៅត្រឹម ២តឹក |

## ៤.៣- ការប្រមូលទិន្នន័យ ក្នុងអំឡុងពេលចិញ្ចឹមត្រី

### ការចំណាយសរុប ក្នុងរយៈពេលចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

| លរ | ការបរិយាយ | ឯកត្តា | ចំនួន | តម្លៃឯកត្តា (៛) | តម្លៃសរុប (៛) | រយៈពេលអនុវត្ត (ថ្ងៃ) |
|---|---|---|---|---|---|---|
| | ការជីកស្រះ | | | | | |
| | ជីកស្រះថ្មី | ម៣ | | | | |
| | ការរៀបចំស្រះ | | | | | |
| ១ | ថ្លៃឈ្នួលបូមទឹក | ម៉ោង | | | | |
| ២ | កំបោរ | គ.ក្រ | | | | |
| ៣ | ជីអ៊ុយរ៉េ | គ.ក្រ | | | | |
| ៤ | ជីដេអាប៉េ | គ.ក្រ | | | | |
| ៥ | លាមកសត្វគោ ក្របី មាន់ ទា | គ.ក្រ | | | | |
| ៦ | ជីរុក្ខជាតិបៃតង | គ.ក្រ | | | | |

DRAFT

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | ............................................. | គ.ក្រ | | | | |
| | សរុប | | | | | |
| | ការដាក់កូនត្រីចិញ្ចឹម | | | | | |
| ១ | ត្រីទីឡាព្យ៉ា | ក្បាល | | | | |
| ២ | ត្រីឆ្ពិន | ក្បាល | | | | |
| ៣ | ត្រីកាបស | ក្បាល | | | | |
| ៤ | ត្រីកាបសាមញ្ញ | ក្បាល | | | | |
| ៥ | ត្រីកាបឥណ្ឌា | ក្បាល | | | | |
| ៦ | ...................................... | ក្បាល | | | | |
| | សរុប | | | | | |
| | ការផ្តល់ចំណីបន្ថែម | | | | | |
| ១ | កន្ទក់ | គ.ក្រ | | | | |
| ២ | ចុងអង្ករ | គ.ក្រ | | | | |
| ៣ | ម្សៅត្រី | គ.ក្រ | | | | |
| ៤ | ចក | គ.ក្រ | | | | |
| ៥ | កណ្តៀរ | គ.ក្រ | | | | |
| ៦ | កាកសំណល់បន្លែ | គ.ក្រ | | | | |
| ៧ | ជន្លេន | គ.ក្រ | | | | |
| ៨ | ......................................... | គ.ក្រ | | | | |
| | សរុប | | | | | |
| | ការគ្រប់គ្រងស្រះ | | | | | |
| ១ | ជីអ៊ុយរ៉េ | គ.ក្រ | | | | |
| ២ | ជីដេអាប៉េ | គ.ក្រ | | | | |
| ៣ | លាមកសត្វគោ ក្របី មាន់ ទា | គ.ក្រ | | | | |
| ៤ | ជីរុក្ខជាតិបៃតង | គ.ក្រ | | | | |
| ៥ | ......................................... | គ.ក្រ | | | | |
| | សរុប | | | | | |
| | ការចំណាយផ្សេងៗ | | | | | |
| ១ | ហាប៉ា (2m x 3m x 1m) | ចំនួន | | | | |
| ២ | ចំណីបន្ថែមសម្រាប់កូនត្រីទីឡាព្យ៉ា | គ.ក្រ | | | | |
| ៣ | ......................................... | | | | | |
| | សរុប | | | | | |

DRAFT

| | | | | | | |
|---|---|---|---|---|---|---|
| | សរុបរួម | | | | | |

ប្រាក់ចំណូលបានពីការចិញ្ចឹមត្រី

| ប្រភេទត្រី | ការប្រមូលផល សម្រាប់ហូបម្ហូបម្ហូបបន្តទម្លាល | | | | ការប្រមូលផលសរុប សម្រាប់លក់ | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ទំងន់ | តម្លៃឯកត្តា | សរុប | ចំនួន | ទំងន់ | តម្លៃឯកត្តា | សរុប | |
| | (ក្បាល) | (គ.ក្រ) | (៛/គ.ក្រ) | (រៀល) | (ក្បាល) | (គ.ក្រ) | (៛/គ.ក្រ) | (រៀល) | ($) |
| ត្រីទីឡាព្យ៉ា | | | | | | | | | |
| ត្រីកាបសាមញ្ញ | | | | | | | | | |
| ត្រីកាបស | | | | | | | | | |
| ត្រីឆ្ពិន | | | | | | | | | |
| ត្រីកាបឥណ្ឌា | | | | | | | | | |
| សរុប | | | | | | | | | |

ប្រាក់ចំណេញពីការចិញ្ចឹមត្រី

| លរ | ការបរិយាយ | ឯកត្តា | ចំនួន | តម្លៃឯកត្តា (៛) | តម្លៃសរុប (៛) | រយៈពេលអនុវត្ត (ថ្ងៃ) |
|---|---|---|---|---|---|---|
| | ការចំណាយ | | | | | |
| ១ | ដីកស្រះចិញ្ចឹមត្រី | ម៣ | | | | |
| ២ | ការរៀបចំស្រះ | | | | | |
| ៣ | ការដាក់កូនត្រីចិញ្ចឹម | ក្បាល | | | | |
| ៤ | ការផ្តល់ចំណីបន្ថែម | គ.ក្រ | | | | |
| ៥ | ការគ្រប់គ្រងស្រះ | | | | | |
| ៦ | ផលិតកម្មកូនត្រីទីឡាព្យ៉ា | | | | | |
| ៧ | ការចំណាយផ្សេងៗ | | | | | |
| | សរុប | | | | | |
| | ការចំណូល | | | | | |
| ១ | ផលត្រីទុកហូប | គ.ក្រ | | | | |
| ២ | ផលត្រីទុកលក់ | គ.ក្រ | | | | |
| ៣ | ផលិតផលកូនត្រីទីឡាព្យ៉ា | ក្បាល | | | | |
| ៤ | ផលត្រីទុកដាក់ចិញ្ចឹមបន្ត | ក្បាល | | | | |
| | សរុប | | | | | |
| | ផលចំណេញ | | | | | |
| | ប្រាក់ចំណូល — ប្រាក់ចំណាយ | | | | | |

DRAFT

៤.៤- ការចំណាយសម្រាប់ការធ្វើបង្ហាញបច្ចេកទេសចិញ្ចឹមត្រី (សម្រាប់ស្រះទំហំ ១០០ម២ រយះពេល ៨ ខែ)

| លរ | ការបរិយាយ | ឯកត្តា | ចំនួន | សេចក្តីបញ្ជាក់ |
|---|---|---|---|---|
| | **ការរៀបចំស្រះ** | | | |
| ១ | ថ្លៃឈ្នួលបូមទឹក | ម៉ោង | 3 | រយះពេលបូមទឹក ខុសៗគ្នា អាស្រ័យនឹងមាឌទឹកស្រះដែលមាន |
| ២ | កំបោរ | គ.ក្រ | 10 | |
| ៣ | ជីអ៊ុយរ៉េ | គ.ក្រ | 1.5 | |
| ៤ | ជីដេអាប៉េ | គ.ក្រ | 0.5 | |
| ៥ | លាមកសត្វគោ ក្របី មាន់ ទា | គ.ក្រ | 40 | ឬ ៤ បង្គី |
| ៦ | ជីរុក្ខជាតិបៃតង | គ.ក្រ | 10 | ឬ ៤ បាច់ ទន្រ្ទេងខេត្ត |
| | **ការដាក់កូនត្រីចិញ្ចឹម** | | | |
| ១ | ៤ ប្រភេទ | ក្បាល | 300 | ទីឡាព្យ៉ា- ឆ្ពិន- កាបស- កាបសាមញ្ញ |
| | **ការផ្តល់ចំណីបន្ថែម** | | | |
| ១ | កន្ទក់ | គ.ក្រ | 20 | បរិមាណចំណីបន្ថែមអាចផ្លាស់ប្តូរ អាស្រ័យនឹងលទ្ធភាពរបស់ |
| ២ | ចក | គ.ក្រ | 50 | កសិករម្នាក់ៗ ។ បើសិនកសិករផ្តល់ចំណីឱ្យត្រីមានបរិមាណច្រើន |
| ៣ | កណ្តៀរ | គ.ក្រ | 5 | ជាងនេះ នោះទិន្នផលត្រីចិញ្ចឹមនឹងទទួលបានផលច្រើនជាង៣០គ.ក្រ |
| ៤ | កាកសំណល់បន្លែ | គ.ក្រ | 10 | |
| | **ការគ្រប់គ្រងស្រះ** | | | |
| ១ | ជីអ៊ុយរ៉េ | គ.ក្រ | 1.5 | |
| ២ | ជីដេអាប៉េ | គ.ក្រ | 0.5 | |
| ៣ | លាមកសត្វគោ ក្របី មាន់ ទា | គ.ក្រ | 40 | |
| ៤ | ជីរុក្ខជាតិបៃតង | គ.ក្រ | 10 | |
| ៥ | ការបូមទឹកបន្ថែមបញ្ចូលស្រះ | | | ក្នុងករណី ទឹកក្នុងស្រះរីងជិតអស់ មុនពេលប្រមូលផលត្រី |
| | **ការប្រមូលផលត្រី ក្រោយចិញ្ចឹម រយះពេល ៨ ខែ** | គ.ក្រ | 30-36 | ទិន្នផលត្រីចិញ្ចឹមអាចប្រែប្រួល អាស្រ័យនឹងការគ្រប់គ្រង |

DRAFT

## ៤.៥- ទីកន្លែងផលិតកូនត្រីពូជនៅប្រទេសកម្ពុជា

### ៤.៥.១ - ស្ថានីយផលិតកូនត្រីពូជ របស់រាជរដ្ឋាភិបាល

| លរ | ឈ្មោះខេត្ត | ចំនួនស្ថានីយ | ឈ្មោះស្ថានីយ អាសយដ្ឋាន | ទំនាក់ទំនង | ទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | ១ | ច្រាំងចំរេះ | លោក. ឃាត់ សុឃន | 011 707 067 |
| | | ១ | ចាក់អង្រែ | លោក. តាំង ផុនអេង | 011 855 685 |
| ២ | កណ្តាល | ១ | ទួលក្រសាំង | លោក. ប៉ែន រដ្ឋា | 012 845 050<br>023 364 751 |
| ៣ | ព្រៃវែង | ១ | បាទី | លោក. ង៉ាន់ ហេង | 012 914 144 |
| ៤ | ស្វាយរៀង | ១ | ប្រាសូត | លោក. រស់ ធីម | 012 902 718 |
| ៥ | តាកែវ | ១ | ខ្សឹង | លោក. អ៊ុក ហាក់ | 012 311 012 |
| ៦ | កំពង់ស្ពឺ | ១ | មន្ទីរកសិកម្មខេត្ត | លោក. ផុន ប៊ិច | 016 787 656 |
| ៧ | សៀមរាប | ១ | ទឹកវិល | លោក. ព្រិន សារិន | 012 821 584 |
| ៨ | ពោធិសាត់ | ១ | Ou Srang Touch | លោក. ប៉ែន ផាន់ណារិទ្ធ | 012 918 714 |
| ៩ | បាត់ដំបង | ១ | វត្តស្លាកែត | លោក. ហុង ហ៊ី | 016 755 004 |
| ១០ | បន្ទាយមានជ័យ | ១ | វត្តស្វាយ | លោក. សោម សុវណ្ណ | 012 777 430 |
| ១១ | ឧត្តរមានជ័យ | ១ | គោករំដួល | លោក. អ៊ុន ចាន់ធី | 011 715 877 |
| ១២ | ប៉ៃលិន | ១ | | លោក. គង់ សុខា | 016 777 023 |
| ១៣ | កំពត | ១ | ឈូក | លោក. ខែម វ៉ាន់ដេត | 092 805 109 |

## ៤.៥.២ - ស្ថានីយផលិតកូនត្រីពូជ ឯកជន

| លរ | ឈ្មោះខេត្ត | ចំនួនស្ថានីយ | ភូមិ ឃុំ ស្រុក | ទំនាក់ទំនង | ទូរស័ព្ទ |
|---|---|---|---|---|---|
| ១ | ស្វាយរៀង | ១ | នារទែន- ឈើទាល- ស្វាយជ្រំ | លោក. សំ វាសនា | 012 846 023 |
| | | ១ | កណ្តាល -ចេក -ស្រុកស្វាយជ្រំ | លោក. រាជ សុភាព | 016 636 870<br>016 636 871<br>011 857 949 |
| | | ១ | ចំលង- ចំលង- ស្វាយជ្រំ | លោក. ធាន វណ្ណា | |
| | | ១ | | លោក. ឡឹក សុភ័ក្រ | 012 783 302 |
| | | | | លោក មាស ពុត | 012 180 3994 |
| ២ | តាកែវ | ១ | ត្រពាំងត្រាច- លាបូ- ត្រាំកក់ | លោក. ខៀវ សំ | 012 415 220 |
| | | ១ | ព្រៃកប្បាស- តាភេម- ត្រាំកក់ | លោក. សោម ហាក់ | 012 583 015 |
| | | ១ | ទឹកថ្លា- គួស- ត្រាំកក់ | លោក. រិន ឈឿន | 092 900 352<br>012 843 725 |
| | | ១ | ទួលស្លែង- ក្រាំងលាវ- បាទី | លោក. ឈីវ ញឹង | 012 510 904 |
| | | ១ | អូផុត- អង្គតាសោម- ត្រាំកក់ | លោក. វ៉ាន់ ប៊ូ | |
| | | ១ | ព្រៃត្រាច- ឧត្តមសូរិយា- ត្រាំកក់ | លោក. មិន សៅ | |
| | | ១ | ពេជ្រចង្វា- បឹងត្រាញ់ខាងជើង- សំរោង | លោក. វឿន | |

DRAFT

| | | | | | |
|---|---|---|---|---|---|
| | | ១ | ព្រៃសំបួរ- អង្គបូរី- អង្គបូរី | លោក. ព្រំ វ៉ាត | 092 253 785 |
| | | ១ | តាសូ- ឧត្តមសូរិយា- ត្រាំកក់ | លោក. សួន សុធា | |
| | | ១ | ព្រៃរំដួល- ត្រពាំងធំខាងត្បូង- ត្រាំកក់ | លោក. អ៊ូច ហឿន | 012 529 095 |
| | | ១ | ព្រៃតាឡី- ត្រពាំងធំខាងជើង- ត្រាំកក់ | លោក. ឡុង យស់ | 012 179 7465 |
| | | ១ | ពោធិតាម៉ុក- អង្គប្រាសាទ- គិរីវង្ស | លោក. ម៉ែន ហុន | 092 640 260 |
| ៣ | កំពង់ស្ពឺ | ១ | បាទី- ព្នាយ- សំរោងទង | លោក. សំ ផល | |
| | | ១ | ត្រពាំងឈូក- និទាន- បរសេដ្ឋ | លោក. កែន ហេង | 012 410 215 |
| | | ១ | ច្រេស- ទឹកល្អក់- គងពិសី | លោក. អួន វ៉ាត | |
| | | ១ | ឈូកស- ព្រៃញាតិ- គងពិសី | លោក. យ៉ាង អ៊ូ | 016 316 500 |
| | | ១ | ក្រោលក្រសាំង- កាត់ភ្លុក- បរសេដ្ឋ | លោក. កែវ នីម | |
| | | ១ | ត្រពាំងលាប- ផុង- បរសេដ្ឋ | លោក. ឌុល លី | 012 179 6241 |
| | | ១ | ព្រៃស្តេច- វាល- គងពិសី | លោក. ឌី សុភី | 012 598 721 |
| | | ១ | តាសោមអក- ភារីមានជ័យ- បរសេដ្ឋ | លោក. ឯក កែវ | |
| ៤ | ព្រៃវែង | ១ | ពោធិតាមុំ- ស្វាយជ្រំ- មេសាង | លោក. ចក់ សម្បត្តិ | 012 731 180 |
| | | ១ | ត្នោត- ឈើកាច់- បាភ្នំ | លោក. ហុង នឿន | |
| | | ១ | ពានាផ្សា- ក្តឿងរាយ- កាញ្ជ្រៀច | លោក. ច័ន្ទ សុជាតិ | |
| | | ១ | អន្លូងស- រំលេច- ស៊ីធរកណ្តាល | លោក. សំ ភ្សៀច | |
| | | ១ | ធ្នង់- ជាខ្លាង- ព្រៃវែង | លោក. ផេង រី | 012 778 437 |
| | | ១ | ច្រេស- ជាខ្លាង- ព្រៃវែង | លោក. ភុម ហ៊ុន | |
| | | ១ | តាគោក- ល្វា- ព្រះស្តេច | លោក. គិត ឡូញ | 092 614 160 |
| | | ១ | អំពិល- សេនារាជឧត្តម- ព្រះស្តេច | លោក. ខេត្ត មុត | |
| | | ១ | ………, រំចេក- ព្រះស្តេច | លោក. យិន ទ្រី | |
| | | ១ | ត្រពាំងរវេ- ជ្រៃ- កំពង់ត្របែក | លោក. អ៊ុយ ជូ | 016 352 378 |
| | | ១ | ស្វាយប៉ាក- ជ្រៃ- កំពង់ត្របែក | លោក. ពុត រិន | |
| | | ១ | ឬស្សីក្អែក- បឹងព្រះ- បាភ្នំ | លោក. លី សុផល | 092 258 934 |
| ៥ | កំពត | ១ | ត្រពាំងរាំង- អង្គរមាស- ដងទង់ | លោក. ញ៉ែត ខុន | |
| | | ១ | ក្រាំងអំពៅ- ដំណាក់សុក្រំ- ដងទង់ | លោក. ម៉ឹង មាន | 012 194 5098 |
| | | ១ | ក្រាំងស្បូវ- ក្រាំងស្បូវ- ឈូក | លោក. យាន អេន | |
| | | ១ | តាណន់- ក្រាំងស្នាយ- ឈូក | លោក. ផឹង សារិន | |
| | | ១ | ស្ពានប្រាំពីរ — ម៉ាក់ប្រាង្គ — កំពត | លោក សរ សូរិន | 012 932 909<br>012 820 910<br>016 334 915 |
| ៦ | ព្រះវិហារ | ១ | ............-..........- ត្បែងមានជ័យ | លោក. ប៉ែន វាសនា | 011 734 738 |

DRAFT

| | | | | | |
|---|---|---|---|---|---|
| | | | តាំងក្រក- របៀប- រវៀង | លោក. សៀ គួយ | 092 286 948 |
| ៧ | **ឧត្តរមានជ័យ** | ១ | | លោក. លិញ រ័ត្ន | 012 18 10 907 |
| ៨ | **រតនះគិរី** | ១ | | លោក. សាន់ សយ | 012 43 96 76 |

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ២០០ វិថីព្រះនរោត្តម ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧

ទូរសារ: ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១

អ៊ីម៉ែល: kunso@camnet.com.kh ឬ mak_soeun@camnet.com.kh

DRAFT